# ពុទ្ធដំណើរត្រាស់ដឹង

# និង

# ធម្មចក្កប្បវត្តនសូត្រ

*រៀបរៀងដោយ*

**ធម្មានន្ទ អ៊ាន់ ចាន់សារ៉ែន**

*ការផ្សាយរបស់ពុទ្ធិកបណ្ឌិតសភា*

*នៃសាកលវិទ្យាល័យបញ្ញាសាស្ត្រកម្ពុជា*

*ព.ស.២៥៥៣*

ឈ្មោះសៀវភៅ ពុទ្ធដំណើរត្រាស់ដឹង និងធម្មចក្កប្បវត្តនសូត្រ

រៀបរៀងដោយ ធម្មានន្ទ វ៉ាន់ ចាន់សារ៉ែន អគ្គលេខាធិការ នៃពុទ្ធិកបណ្ឌិតសភា

កាលបរិច្ឆេទ ថ្ងៃ អង្គារ ១៥ កើតពេញបូណ៌មី ខែអាសាឍ ព.ស. ២៥៥៣ ត្រូវនឹងថ្ងៃទី ៧ ខែ កក្កដា គ.ស.២០០៩

បោះពុម្ពដោយ ពុទ្ធបរិស័ទទូទៅ

បោះពុម្ពចំនួន ១,០០០ ក្បាល

Printed for free distribution by
**The Corporate Body of the Buddha Educational Foundation**
11F., 55 Hang Chow South Road Sec 1, Taipei, Taiwan, R.O.C.
Tel: 886-2-23951198 , Fax: 886-2-23913415
Email: overseas@budaedu.org
Website:http://www.budaedu.org
Mobile Web: m.budaedu.org

**This book is strictly for free distribution, it is not to be sold.**
សម្រាប់ចែកជាធម្មទាន

# អារម្ភកថា

ថ្ងៃ ១៥ កើតពេញបូណ៌មី ខែ អាសាឍ ជាថ្ងៃពិសេសមួយក្នុងព្រះពុទ្ធសាសនា ៖

-ជាថ្ងៃព្រះពុទ្ធជាម្ចាស់ ព្រះអង្គទ្រង់យាងចុះចាប់បដិសន្ធិ

-ជាថ្ងៃព្រះពុទ្ធជាម្ចាស់ ព្រះអង្គទ្រង់យាងសាងព្រះផ្នួស

-ជាថ្ងៃព្រះពុទ្ធជាម្ចាស់ ព្រះអង្គទ្រង់ប្រកាសសម្ដែងបឋមទេសនា គឺធម្មចក្កប្បវត្តនសូត្រ ដែលជាធម្មរតនៈក្នុងលោក

-ជាថ្ងៃព្រះសង្ឃរតនៈកើតឡើងក្នុងលោក

-ជាថ្ងៃព្រះពុទ្ធជាម្ចាស់ ព្រះអង្គទ្រង់សម្ដែងយមកបាដិហារ្យក្នុងក្រុងសាវត្ថី ។

អាស្រ័យហេតុនេះហើយ ទើបពុទ្ធិកបណ្ឌិតសភានៃសាកលវិទ្យាល័យបញ្ញាសាស្ត្រកម្ពុជា ដែលមានលោកបណ្ឌិត **ភួល ផេង** ជាប្រធានក្រុមប្រឹក្សាភិបាល បានព្រមព្រៀងគ្នាបង្កើតនូវកម្មវិធីជួបជុំព្រះសង្ឃ និងពុទ្ធបរិស័ទស្វាធ្យាយ និងធម្មសាកច្ឆាក្នុងធម្មចក្កប្បវត្តនសូត្រ នៅថ្ងៃ ១៥ កើតពេញបូណ៌មី ខែ អាសាឍ ឆ្នាំ ឆ្លូវ ឯកស័ក ព.ស.២៥៥៣ ត្រូវនឹងថ្ងៃទី ៧ ខែ កក្កដា គ.ស.២០០៩ ។

កម្មវិធីនេះប្រារព្ធឡើង ដើម្បីរំលឹកដល់ព្រះធម្មរតនៈ និងព្រះសង្ឃរតនៈ ដែលកើតមានក្នុងថ្ងៃ ១៥ កើតពេញបូណ៌មី ខែ អាសាឍនេះ ។

ចិរំ សទ្ធម្មោ តិដ្ឋតុ

*សូមព្រះសទ្ធម្មតាំងនៅអស់កាលដ៏យូរ!*

សព្វេ សត្តា អវេរិនោ ហោន្តុ

*សូមសត្វលោកទាំងឡាយ កុំមានពៀរនឹងគ្នា*

សព្វេ សត្តា ខេមិនោ ហោន្តុ

*សូមសត្វលោកទាំងឡាយ បានដល់នូវសេចក្តីក្សេម*

សព្វេ សត្តា សុខិនោ ហោន្តុ

*សូមសត្វលោកទាំងឡាយបានប្រកបដោយសេចក្តីសុខជានិច្ចនិរន្តរ៍!*

*ថ្ងៃ ១៥ កើត ខែ អាសាឍ ព.ស.២៥៥៣*

*ត្រូវនឹងថ្ងៃទី ៧ ខែ កក្កដា គ.ស.២០០៩*

**ធម្មានន្ទ ហ៊ាន់ ចាន់សារ៉ែន**

*អគ្គលេខាធិការពុទ្ធិកបណ្ឌិតសភា*

# សម្មោទនីយកថា

ខ្ញុំព្រះករុណា ខ្ញុំបាទមានចិត្តរំភើបរីករាយប្រកបដោយបីតិសោមនស្ស យ៉ាងខ្លាំង ចំពោះការប្រារព្ធពិធីបុណ្យអាសាឡ្ហបូជានេះ ។ ក្នុងកម្មវិធីនេះទៀតសោត មានការស្វាធ្យាយធម្មចក្កប្បវត្តនសូត្រ និងកម្មវិធីសន្ទនាព្រះធម៌ ដែលជាប់ទាក់ទងក្នុងធម្មចក្កប្បវត្តនសូត្រ ។ នេះជាប្រវត្តិសាស្ត្រទី ១ សម្រាប់ពុទ្ធិកបណ្ឌិតសភានៃសាកលវិទ្យាល័យបញ្ញាសាស្ត្រកម្ពុជា ដែលមានខ្ញុំព្រះករុណា ខ្ញុំបាទ ជាប្រធានក្រុមប្រឹក្សាភិបាល ។ ខ្ញុំព្រះករុណា ខ្ញុំបាទសង្ឃឹមមាំថា ពុទ្ធិកបណ្ឌិតសភានឹងរៀបចំនូវកម្មវិធីនេះ រៀងរាល់ឆ្នាំក្នុងថ្ងៃ ១៥ កើតពេញបូណ៌មី ខែ អាសាឍ ដើម្បីជួបជុំព្រះសង្ឃ និងពុទ្ធបរិស័ទស្វាធ្យាយធម្មចក្កប្បវត្តនសូត្រ ។

ខ្ញុំព្រះករុណា ខ្ញុំបាទសូមថ្លែងអំណរអរព្រះគុណ និងអរគុណដ៏ជ្រាលជ្រៅ ចំពោះព្រះថេរានុត្ថេរៈគ្រប់ព្រះអង្គ និងពុទ្ធសាសនិកជនគ្រប់រូប ដែលបានគាំទ្រនិងជួយឧបត្ថម្ភនូវកម្មវិធីរបស់ពុទ្ធិកបណ្ឌិតសភានៃសាកវិទ្យាល័យបញ្ញាសាស្ត្រកម្ពុជា ។

ដោយគុណានុភាពនៃព្រះរតនត្រ័យ សូមព្រះថេរានុត្ថេរៈគ្រប់ព្រះអង្គ និងពុទ្ធបរិស័ទជួបប្រសព្វនូវធម៌ដ៏ប្រសើរគឺ អាយុ វណ្ណៈ សុខៈ និងពលៈ កុំបីឃ្លៀងឃ្លាតឡើយ ។

ថ្ងៃ ១៥ កើត ខែ អាសាឍ ព.ស.២៥៥៣

ត្រូវនឹងថ្ងៃទី ៧ ខែ កក្កដា គ.ស.២០០៩

**បណ្ឌិត ក្មុល ផេង**

ប្រធានក្រុមប្រឹក្សាភិបាលនៃពុទ្ធិកបណ្ឌិតសភា



# ពុទ្ធដំណើរត្រាស់ដឹង

*ព្រះសិទ្ធត្ថពោធិសត្វខំប្រឹងប្រព្រឹត្តនូវតបកម្ម ជាទុក្ករកិរិយា ដែលសត្វលោកធ្វើបានដោយលំបាក នាដងក្នុងដង្កើស្វារី ។ បញ្ចវគ្គិយតាបសទាំង ៥ រូប មានកោណ្ឌញ្ញៈ ភទ្ទិយ វប្បៈ មហានាម អស្សជិ ជាអ្នកខ្វល់ខ្វាល់ក្នុងកិច្ចប្រព្រឹត្តតបកម្ម ដោយយល់ឃើញថា ការប្រព្រឹត្តធ្វើយ៉ាងនេះនឹងបានសម្រេចនូវមោក្ខធម៌ ជាទីក្សេម រួចផុតចាកកិលេសទាំងពួងមិនខាន ។ តែអត្តកិលមថានុយោគនោះ ដែលព្រះពោធិសត្វខំប្រឹងប្រព្រឹត្តអស់ ៦ ឆ្នាំ មិនបានសម្រេចជាប្រយោជន៍អ្វីទាំងអស់ ក្រៅពីប្រព្រឹត្តខ្លួនឲ្យជាទុក្ខនោះឡើយ ។ ថ្ងៃមួយព្រះពោធិសត្វពិចារណាថា ជនអ្នកបំពេញទុក្ករកិរិយាក្នុងលោកនេះ ប្រាកដស្មើដោយយើងមិនមានឡើយ ជនដែលអាចបំពេញទុក្ករកិរិយាឲ្យក្រៃលែងជាងនេះ ក៏មិនមានដែរ នេះមិនមែនជាផ្លូវត្រាស់ដឹង ការយើងអង្គុយបំពេញសមាធិក្រោមដើមព្រីងនោះ ជាផ្លូវត្រាស់ដឹងទេដឹង? យើងមានរាងកាយខ្សោយទ្រុឌទ្រោមយ៉ាងនេះ មិនអាចចម្រើនសមាធិនោះបានឡើយ បើដូច្នោះ មានតែអាត្មាអញទំនុកបម្រុងរាងកាយ ដោយការបរិភោគអាហារ ទើបអាចចម្រើនសមាធិបាន ។ ពេលនោះ ព្រះពោធិសត្វកាន់បាត្រ ចូលទៅបិណ្ឌបាតក្នុងសេនានិគមហើយឆាន់ចង្ហាន់ត្រឹមពីរបីថ្ងៃ ព្រះវរកាយដ៏មានកម្លាំង ប្រកបដោយមហាបុរិសលក្ខណៈ ៣២ ប្រការ មានពណ៌សម្បុរដូចជាមាសប្រក្រតីឡើងវិញ ។*

*គ្រានោះ ពួកបញ្ចវគ្គិយតាបសនាំគ្នាគិតថា មហាបុរសនេះ បំពេញទុក្ករកិរិយាដល់ទៅ ៦ ឆ្នាំ ក៏នៅមិនអាចធ្វើឲ្យជាក់ច្បាស់នូវសព្វញ្ញុតញ្ញាណ*

ឥឡូវនេះ ត្រេចទៅបិណ្ឌបាតក្នុងស្រុក និងនិគមជាដើម សោយអាហារ តើ នឹងអាចត្រាស់ដឹងបានដូចម្តេចទៅ ! មហាបុរសនេះ ជាអ្នកប្រាថ្នាលាមក ឃ្លៀងឃ្លាតចាកព្យាយាម តើមានប្រយោជន៍អ្វី ដែលពួកយើងនៅជាមួយ មហាបុរសនេះទៀត ។ កាលពួកបញ្ចវគ្គិយតាបសទាំងនោះគិតគ្នាយ៉ាង នេះហើយ ក៏នាំគ្នាលះបង់ព្រះពោធិសត្វ ទៅនៅក្នុងព្រៃឥសិបតនមិគទាយ វ័ន បំពេញទុក្ករកិរិយាបន្តទៀត ។

ក្នុងពេលជិតភ្លឺថ្ងៃ ១៤ កើត ព្រះពោធិសត្វទ្រង់ឃើញមហាសុបិន ជាបុព្វនិមិត្ត ៥ ប្រការគឺ

១-ព្រះពោធិសត្វទ្រង់សុបិនឃើញ ព្រះអង្គសឹងលើមហាប្រឹថពី ស្តេចភ្នំឈ្មោះហិមវន្តជាខ្នើយ ព្រះហស្តឆ្វេងសណ្តូកចុះ ក្នុងសមុទ្រខាង កើត ព្រះហស្តស្តាំសណ្តូកចុះ ក្នុងខាងលិច ព្រះបាទទាំងគូសណ្តូកចុះ ក្នុង សមុទ្រខាងត្បូង ។

២- ព្រះពោធិសត្វទ្រង់សុបិនឃើញ ស្មៅចិញ្ចៀន ១ សរសៃ ដុះ លេចអំពីផ្ចិតទៅទល់នឹងអាកាស ។

៣- ព្រះពោធិសត្វទ្រង់សុបិនឃើញ មានពួកសត្វដង្កូវខ្លួនស ក្បាល ខ្មៅ វារចេញអំពីព្រះបាទទាំងគូ ចាប់ដើមអំពីចុងក្រចក ហោមរោមជិត ដរាបដល់មណ្ឌលនៃជង្គង់ ។

៤-ព្រះពោធិសត្វទ្រង់សុបិនឃើញ មានសត្វបក្សី ៤ ពួក មាន សម្បុរផ្សេងៗ គ្នា ហើរមកអំពីទិសទាំង ៤ មកក្រាបចុះ ទៀបបាទមូល ក៏ ត្រឡប់ជាមានសម្បុរសទាំងអស់ទៅវិញ ។

៥-ព្រះពោធិសត្វទ្រង់សុបិនឃើញ ព្រះអង្គចង្ក្រមលើភ្នំលាមកដ៏ធំ មិនបានប្រឡាក់ដោយលាមកឡើយ ។

**អត្ថន័យមហាសុបិន**

១-ព្រះអង្គពិតជាបានត្រាស់ដឹងនូវអនុត្តរសម្មាសម្ពោធិញ្ញាណ ពិតប្រាកដ

២-មគ្គប្រកបដោយអង្គ ៨ ដែលព្រះអង្គត្រាស់ដឹងហើយ មនុស្ស និងទេវតាអាចប្រកាសបានដោយប្រពៃ

៣-ពួកគ្រហស្ថស្លៀកពាក់ស នឹងដល់ព្រះអង្គជាសរណៈស្មើ ដោយជីវិត

៤-វណ្ណៈទាំង ៤ គឺ ខត្តិយៈ ព្រាហ្មណ៍ វេស្សៈ និងសូទ្រៈ ទាំង ៤ វណ្ណៈនេះ ចេញចាកផ្ទះមកបួសក្នុងធម៌វិន័យ ដែលព្រះអង្គទ្រង់សម្ដែងហើយ ធ្វើឲ្យជាក់ច្បាស់នូវវិមុត្តិដ៏ប្រសើរ

៥-លាភសក្ការៈដែលកើតឡើងចំពោះព្រះអង្គហើយ ព្រះអង្គមិនបានជាប់ដោយលាភសក្ការៈនោះឡើយ ។

មហាបុរសគ្រាទ្រង់ឃើញមហាសុបិន ៥ យ៉ាងនេះ ទ្រង់កែសុបិនដោយព្រះអង្គឯងថា ថ្ងៃនេះ យើងនឹងបានត្រាស់ដឹងជាព្រះពុទ្ធ ពិតប្រាកដ ឥតមានអ្វីគួរឲ្យសង្ស័យឡើយ ។ កាលអរុណរះឡើងក្នុងថ្ងៃ ១៥កើតពេញបូណ៌មី ព្រះអង្គយាងទៅគង់ក្រោមដើមអជបាលនិគ្រោធ រង់ចាំវេលាត្រេចទៅបិណ្ឌបាត ។

គ្រានោះ នាងសុជាតាជាម្តាយយសកុលបុត្រ ដែលជាធីតារបស់លោកសេនានីកុដុម្ពី ក្នុងស្រុកសេនានិគម ត្រង់តំបន់ឧរុវេលា ធ្លាប់បានតាំងសេចក្តីប្រាថ្នាត្រង់គល់និគ្រោធ(ដើមជ្រៃ)នោះ ហើយមានបំណងយកមធុបាយាសទៅសែន ទើបប្រើនាងបុណ្ណាទាសី ជាមេដោះរបស់ខ្លួនទៅសំអាតក្រោមដើមជ្រៃនោះ ។ កាលនាងបុណ្ណាទាសី ទៅដល់ទីនោះ បានឃើញព្រះពោធិសត្វកំពុងគង់បែរព្រះភក្ត្រទៅទិសខាងកើត មានព្រះវរកាយរុងរឿងដោយពន្លឺ ទើបមានសេចក្តីត្រិះរិះថា ទេវតារបស់ពួកយើងមករង់ចាំទទួលនូវពលីកម្មរបស់ពួកយើង ហើយត្រឡប់ទៅប្រាប់នាងសុជាតា តាមអ្វីដែលខ្លួនបានឃើញ ។

លំដាប់នោះ នាងសុជាតាកើតសទ្ធាព្រមហើយ បានតាក់តែងនូវគ្រឿងប្រដាប់គ្រប់យ៉ាង ឲ្យមនុស្សដាក់មធុបាយាសដែលមានរសដ៏ត្រកាល ក្នុងថាសមាស ដែលមានតម្លៃ ១០០,០០០ កហាបណៈ ហើយយកតាជីមាសមកគ្របពីលើ ទូលតម្រង់ទៅគល់ដើមជ្រៃ ។ កាលនាងសុជាតាទៅដល់ដើមជ្រៃឃើញព្រះមហាពោធិសត្វ មានពន្លឺល្អល្អះចេញពីព្រះវរកាយ ធ្វើឲ្យដើមឈើទាំងអស់ មានពណ៌ដូចជាមាស ក៏សម្គាល់ថា ជារុក្ខទេវតា ។ ពេលនោះនាងសុជាតាក៏បង្អោនមធុបាយាសទៅក្នុងព្រះហស្តព្រះពោធិសត្វ ហើយពោលថា **យថា មម មនោរថោ និប្ផន្នោ, ឯវំ តុម្ហាកម្បិ មនោរថោ និប្ផជ្ជតុ** មនោរថរបស់ខ្ញុំបានសម្រេចហើយយ៉ាងណា, សូម្បីលោកក៏សូមឲ្យសម្រេចតាមមនោរថយ៉ាងនោះដែរ ។ គ្រាពោលយ៉ាងនេះហើយ នាងសុជាតាក៏ចៀសចេញទៅ ។

លំដាប់នោះព្រះបរមពោធិសត្វទ្រង់កាន់ថាសមាស យាងទៅកាន់មាត់ស្ទឹងនេរញ្ជរា ព្រះអង្គទ្រង់ដាក់ថាសមាសត្រង់កំពង់ទឹកឈ្មោះសុប្បតិដ្ឋៈ ហើយនិមន្តចុះ ។ កាលព្រះអង្គនិមន្តស្រង់ទឹករួចហើយ ទ្រង់ឡើងមកវិញ យាងទៅគង់ក្រោមម្លប់ឈើមួយដ៏សែនត្រជាក់គួរជាទីសប្បាយ ។ ពេលនោះព្រះអង្គពូតបាយមធុបាយាសជាដុំចំនួន ៤៩ ដុំ ហើយទ្រង់ឆាន់បាយាសនោះ ត្រង់កំពង់ស្ទឹងនេរញ្ជរានោះឯង ។ កាលព្រះអង្គទ្រង់ឆាន់ស្រេចហើយ ទ្រង់លើកថាសឡើងព្រមជាមួយនឹងការអធិដ្ឋានថា **សច្ចាហំ អជ្ជ ពុទ្ធោ ភវិស្សាមិ, អយំ សុវណ្ណបាតិ បដិសោតំ គច្ឆតុ ប្រសិនបើក្នុងថ្ងៃនេះអាត្មាអញនឹងបានត្រាស់ជាព្រះពុទ្ធ, សូមឲ្យថាសមាសនេះ អណ្តែតបញ្ច្រាសក្រសែទឹក** ហើយព្រះអង្គក៏បោះថាសមាសចូលទៅក្នុងស្ទឹងនេរញ្ជរា ។ ថាសមាសនោះ បានអណ្តែតបញ្ច្រាសក្រសែទឹកមែន ហើយបានធ្លាក់ចុះទៅដល់ទីលំនៅរបស់កាលនាគរាជ ។ ស្តេចនាគបានយកថាសព្រះពុទ្ធ ៣ អង្គកន្លងទៅហើយ យកមកដាក់ខាងក្រោមថាសមាសនេះ ។

គ្រានោះ ព្រះពោធិសត្វគង់សម្រាកក្នុងវេលាថ្ងៃក្នុងព្រៃសាលព្រឹក្សដែលគួរជាទីរីករាយ មានពណ៌ខៀវស្រស់ មានក្លិនក្រអូបយ៉ាងក្រៃលែងជិតមាត់ស្ទឹងនេរញ្ជរា ទ្រង់បំពេញព្យាយាមរហូតកើតសមាបត្តិ ៨ និងអភិញ្ញា ៥ ហើយព្រះអង្គក្រោកពីព្រៃសាលវ័ន យាងទៅតាមផ្លូវដែលពួកទេវតាតាក់តែងហើយ យាងចុះស្រង់ទឹកក្នុងស្ទឹងនេរញ្ជរា ហើយឆ្លងទៅកាន់ត្រើយម្ខាងទៀត មានព្រះភក្ត្រឆ្ពោះទៅដើមមហាពោធិព្រឹក្ស ។ ពួកទេវតានាគនិងគន្ធព្វជាដើមបាននាំគ្នាបូជាព្រះអង្គ ដោយផ្កាកម្រងនឹងគ្រឿង

ក្រអូប ។ គ្រានោះ សោត្ថិយព្រាហ្មណ៍ជាអ្នករកស្មៅ កាន់ស្បូវស្គាដើរតាមផ្លូវបញ្ច្រាសទិសរបស់ព្រះអង្គ ដឹងអាការៈរបស់មហាបុរស ទើបបានថ្វាយស្បូវស្គា ៨ ក្តាប់ចំពោះព្រះអង្គ ។ ព្រះពោធិសត្វទទួលយកស្បូវស្គាហើយស្តេចយាងចូលទៅកាន់គល់អស្សត្ថព្រឹក្ស (ព្រះមហាពោធិព្រឹក្ស) ដែលជាដើមឈើមានជ័យជម្នះ ដូចកំពូលភ្នំអសិតញ្ជនៈបាំងរស្មីដួងទិវាករ មានម្លប់ត្រជាក់ជាទីគួរសប្បាយ ដូចព្រះទ័យព្រះអង្គត្រជាក់ទៅដោយករុណាប្រាសចាកជំនុំពួកវិហង្គផ្សេងៗ មានស្លឹកត្រសាយត្រសុំ ខ្យល់បក់មកប៉ះរវិចៗ ព្រះអង្គយាងទៅគង់ទិសទក្សិណ ។ ស្ថានទីទិសទក្សិណនោះញាប់ញ័រ ដូចជាតំណក់ទឹកនៅលើស្លឹកឈូក មហាបុរសទ្រង់ត្រិះរិះថា ស្ថានទីនេះ មិនអាចញ៉ាំងគុណវិសេសឲ្យកើតឡើងដល់អាត្មាអញឡើយ ទើបយាងទៅទិសបស្ចិម ។ សូម្បីទិសបស្ចិមនោះ ក៏ញាប់ញ័រដូចគ្នា ។ ស្តេចយាងទៅទិសឧត្តរ ។ សូម្បីទិសឧត្តរនោះ ក៏ញាប់ញ័រដូចគ្នា ។ ពេលនោះព្រះអង្គយាងទៅគង់ទិសបូព៌ ។ ក្នុងទិសបូព៌នេះ មិនញាប់ញ័រអ្វីឡើយ ។ មហាបុរសធ្ងន់ក្នុងចិត្តថា ទីនេះជាទីកម្ចាត់កិលេសពិតប្រាកដ ទើបទ្រង់ឈរទិសព្យសាន ចាប់ចុងស្បូវស្គាអង្រួនដាក់លើដី ។ ខណៈពេលនោះស្រាប់តែក្លាយទៅជាបល្ល័ង្កប្រមាណ ១៤ ហត្ថ ។ ស្បូវស្គាទាំងនោះដូចគេវេញចូលគ្នាដ៏ស្អាតវិចិត្រ ។ មហាបុរសគង់ពែនព្រះភ្នែន ៣ ជាន់[១] លើបល្ល័ង្កនោះ ទ្រង់អធិដ្ឋានសេចក្តីព្យាយាមមានអង្គ ៤ ដោយទ្រង់ត្រិះរិះថា

---

[១] សំដៅដល់គង់យកព្រះហស្តដាក់លើព្រះឧរុ(ភ្លៅ) ១ ព្រះជាណុ (ខ្នងជើង) ១ ចង្កេះត្រង់ ១ រួមជាសណ្ឋាន ៣ ជាន់ ទីឃ.សីលក្ខវគ្គអភិនវដីកា ។

ស្បែក សរសៃ និងឆ្អឹង រីងស្ងួតទៅក៏ដោយ សាច់ និងឈាមក្នុងរាងកាយនឹងរីងស្ងួតទៅក៏ដោយ បើយើងមិនបានចាក់ធ្លុះនូវវត្ថុដែលបុគ្គលគប្បីចាក់ធ្លុះ ដោយកម្លាំងរបស់បុរស ដោយការព្យាយាមរបស់បុរស ដោយការប្រឹងប្រែងរបស់បុរស យើងមិនឈប់ព្យាយាមនោះឡើយ ទ្រង់អធិដ្ឋានបន្តទៀតថា ទោះបីមហាប្រឹថពីនេះក្រឡាប់ក៏ដោយ សូម្បីមានគ្រឿងប្រហារ ១,០០០ ធ្លាក់ចុះមកក៏ដោយ ទោះបីផ្កូវក្នុងព្រៃនេះបែកបាក់ខ្ទិចខ្ទីក៏ដោយ ទោះបីជាដុំគំនរភ្នំធ្លាក់ចុះមកក៏ដោយ បើអាត្មាអញមិនទម្លុះនូវសម្មាសម្ពោធិញ្ញាណ អាត្មាអញនឹងមិនឈប់ព្យាយាមឡើយ ហើយព្រះអង្គទ្រង់គង់ក្រោមគល់មហាពោធិព្រឹក្ស មានព្រះភក្ត្របែទៅទិសខាងកើត ព្រះបិដ្ឋិ (ខ្នង)ព្រះអង្គ បែទៅទិសខាងបស្ចិមនាដើមមហាពោធិព្រឹក្ស ដែលមានខ្នាតប្រមាណ ៥០ ហត្ថ ហាក់ដូចជាមាសប្រាក់ដែលគេដាក់ទុកក្នុងតាំងមាស មានមែកដូចជាឆត្រកែវបាំងពីខាងលើ បណ្តូលពោធិធ្លាក់ចុះលើចីវរដែលមានពណ៌ដូចជាដុំមាស ទីនោះមានពន្លឺរុងរឿងដូចជាកែវប្រពាឡ ដែលគេដាក់ទុកក្នុងផែនមាស ។

គ្រានោះ វសវត្តីមារអ្នកមានអំណាចលើសត្វលោកទាំងអស់ បានលះភាពជាធំលើពួកទេពរបស់ខ្លួនអស់វេលា ៦ ឆ្នាំ ប្រើចិត្តកំណត់ដឹងចិត្តរបស់មហាបុរស ដើម្បីឃ្លាំមើល មិនឃើញសេចក្តីភ្ញាំងភ្ញាត់អ្វីតិចតួច ទើបគិតថា សិទ្ធត្ថនេះ មកអង្គុយក្រោមដើមពោធិ ដើម្បីត្រាស់ដឹងជាព្រះពុទ្ធត្រូវការកន្លងវិស័យរបស់យើង ពេលនេះ យើងមិនឲ្យសិទ្ធត្ថនេះកន្លងវិស័យយើងបានឡើយ ។ កាលណោះ វសវត្តីមារត្រឡប់ទៅកាន់វសវត្តិទេវលោក

ប្រជុំពលមាររបស់ខ្លួនហើយបញ្ជាថា ពួកលោកចូរនិម្មិតខ្លួនជាភេទប្លែកៗ គួរឲ្យខ្លាច កាន់អាវុធផ្សេងៗក្នុងដៃ ហើយនាំគ្នាចូលទៅរកសិទ្ធត្ថ ឲ្យដូចជារលកហូរចូលទៅ ។ ចំណែកវសវត្តីមារខ្លួនឯង ជិះដំរីមេខលា ដែលមានកំពស់ ១៥០ យោជន៍ និម្មិតដៃ ១,០០០ កាន់អាវុធនានា ហើយតម្រង់មករកព្រះពោធិសត្វ ។ ចំណែកបរិស័ទរបស់មារកាន់យកអាវុធផ្សេងៗគ្រប់ដៃ មានដាវ កាំបិត ព្រួញ និងលំពែងជាដើម ពាក់ក្លួងពស់ យកមាត់បៀមពិស ផ្លុំភ្លើងចេញពីមាត់ មានកាយអាក្រាត សម្បុរក្រខ្វក់ និម្មិតភេទផ្សេងៗ ដូចជាប្រេតមានតែគ្រោងឆ្អឹងជាដើម ធ្វើរូបប្លែកៗ គួរឲ្យខ្លាចជាច្រើន ឡោមព័ទ្ធជុំវិញព្រះពោធិសត្វ ។

កាលវសវត្តីមារចូលទៅជិតព្រះបរមពោធិសត្វយ៉ាងនេះ ទេវតាទាំងឡាយ មានសក្កទេវរាជជាដើម សូម្បីត្រឹមមួយអង្គដែលអាចស្ថិតនៅទីនោះ មិនមានឡើយ នាំគ្នារត់ចេញទៅទីដទៃៗ ។ ចំណែកសក្កទេវរាជបាន យកសង្ខវិជយយុត្តដាក់ខាងក្រោយ រត់ទៅរហូតដល់មាត់កណ្ដាប់ចក្កវាឡ ។ មហាព្រហ្មកាន់ស្វេតច្ឆត្រទៅកាន់ព្រហ្មលោក ។ កាលនាគរាជលះបង់ពួកនាគរបាំទាំងឡាយ មុជចុះក្នុងផែនដីរហូតដល់ពិភពនាគដែលមានមណ្ឌប ៥០០ យោជន៍ ហើយដេកយកដៃបិទមុខ ។ កាលណោះ មានតែព្រះពោធិ-សត្វមួយអង្គឯងប៉ុណ្ណោះ មិនមានទេវតាឯណានីមួយ ស្ថិតនៅក្នុងទីនោះឡើយ ដូចព្រហ្មក្នុងសុញ្ញវិមាន ។

ទេវបុត្រមារនោះ ជាឱបបាតិកកំណើត ជាទេវបុត្រធំក្នុងកាមាវចរសួគ៌ ។ ពេលខ្លះអាចចូលសណ្ឋិតក្នុងរាងកាយរបស់ពួកព្រហ្មបារិសជ្ជា

បាន មារនោះ ទើបសម្គាល់ខ្លួនថា យើងជាអ្នកធំជាងសត្វលោកទាំងពួង យើងជាអ្នកប្រសើរជាងទេវតា និងមនុស្សទាំងឡាយ ព្រោះហេតុនោះ ទើបតិះដៀលព្រះអង្គថា សមណៈនេះកើតក្នុងកលលៈពោលគឺគ្រាប់ឈាម សរបស់មនុស្សស្រី ដូចជាដង្កូវកើតក្នុងសាច់ សមណៈនេះមិនដឹងប្រមាណ របស់ខ្លួន ហ៊ានអង្គុយមុខអញ មិនក្រោកចាកទីនេះ ។

ពេលនោះ មារមានចិត្តបាបព្យាយាមចូលទៅជិតព្រះពោធិសត្វ តែ មិនអាចចូលទៅបាន ទើបឈរក្នុងទីនោះបញ្ជាសេនារបស់ខ្លួនថា ពួកឯង ចូលទៅចាប់សមណៈនេះ ។ ពួកសេនារបស់មារមិនអាចចូលទៅជិត ព្រះ ពោធិសត្វបានឡើយ ។

ក្នុងគ្រានោះ មារបានបណ្តាលភ្លៀង ៩ យ៉ាង ដើម្បីញ៉ាំងភ័យឲ្យ កើតឡើង ចំពោះព្រះពោធិសត្វ ។

បណ្តាលឲ្យកើតខ្យល់ព្យុះដែលមានសន្ទុះយ៉ាងខ្លាំង អាចបក់បោក ដើមឈើឲ្យរលំ បក់ថ្មឲ្យប៉ើង អាចបណ្តាឲ្យរបើកដំបូលផ្ទះបាន តែមិន អាចធ្វើ សូម្បីត្រឹមតែជាយចីវរ ព្រះពោធិសត្វឲ្យកម្រើកបានឡើយ ។

បណ្តាលឲ្យកើតធ្លាក់គ្រាប់ភ្លៀងធំៗ មកលើព្រះពោធិសត្វ តែមិន អាចធ្វើសូម្បីឲ្យទទឹកជាយចីវរ ព្រះពោធិសត្វបានឡើយ ។

បណ្តាលឲ្យកើតភ្លៀងរងើកភ្លើងថ្ម ដែលមានកម្តៅដ៏ក្តៅធ្លាក់ចុះមក លើព្រះពោធិសត្វ តែរងើកភ្លើងថ្មនោះ ក្លាយជាកម្រងផ្កាទៅវិញ ។

បណ្ដាលឲ្យកើតភ្លៀងអាវុធមុខមួយ អាវុធមុខពីរ មានសរ លំពែង និងដាវជាដើម ធ្លាក់ចុះពីឰដ៏អាកាស មកលើព្រះពោធិសត្វ តែក្លាយទៅជាកួងផ្កាម្លិះជាដើម រោយរាយធ្លាក់ចុះមកវិញ ។

បណ្ដាលឲ្យកើតភ្លៀងអណ្ដាតភ្លើង ធ្លាក់ចុះពីអាកាស មកលើព្រះពោធិសត្វ ស្រាប់តែក្លាយជាលម្អិតខ្ចឹមចន្ទន៍ ធ្លាក់ចុះមកវិញ ។

បណ្ដាលឲ្យកើតខ្សាច់ធ្លាក់ចុះមក ភ្លៀងខ្សាច់ដ៏ក្ដៅគគុកនោះ ក៏ក្លាយទៅជាកេសរផ្កាធ្លាក់ចុះមកវិញ ។

បណ្ដាលឲ្យភ្លៀងភក់ធ្លាក់ចុះមក ភ្លៀងភក់នោះមានកម្ដៅយ៉ាងខ្លាំងធ្លាក់ចុះមក ស្រាប់តែក្លាយទៅភក់មានក្លិនក្រអូបទៅវិញ ។

បណ្ដាលឲ្យកើតគប់ភ្លើងមានចំនួនច្រើនធ្លាក់ចុះមក កំទេចភ្លើង និងផ្សែងភ្លើងពាសពេញអាកាស រន្ទះបាញ់ចំនួនមួយពាន់ព្ធុកក្រើករំពើកញាប់ញ័រពេញផ្ទៃអាកាសា ។

កាលមារាធិរាជមិនអាចធ្វើអ្វីចំពោះព្រះពោធិសត្វបាន មានបំណងចូលទៅកាត់ព្រះសីសៈព្រះមហាបុរស ទើបចាប់ចក្រាវុធបោះចូលទៅរកព្រះពោធិសត្វ ស្រាប់តែចក្រាវុធនោះធ្លាក់ចុះជិតព្រះបាទ ដូចជាសំពត់ជូតព្រះបាទព្រះអង្គទៅវិញ ។

ព្រះពោធិសត្វសំឡឹងមើលមារ និងសេនារបស់មារដោយមេត្តាចិត្តប្រៀបដូចបិតា សំឡឹងមើលមុខបុត្រ ។

គ្រានោះ ព្រះពោធិសត្វពោលចំពោះមារថា **ន ជានាតិ សយំ មយ្ហំ ទាសការំមប្បយំ ខលោ ម្នាលមារល្ងង់ អ្នកឯងមិនដឹងខ្លួនឯងជាទាសៈរបស់**

យើងសោះ ។ អ្នកឯងជិះដំរីមេខលា មានសេនាដ៏ច្រើន មានបំណងឲ្យយើងឃ្លាតចាកទីនេះ អ្នកឯងមិនអាចធ្វើឲ្យយើងឃ្លាតចាកបល្ល័ង្កនេះបានឡើយ ។

ពេលនោះ វសវត្តីមារសួរព្រះពោធិសត្វថា សិទ្ធត្ថ ហេតុដូចម្តេចលោកទើបមកអង្គុយលើបល្ល័ង្ករបស់យើង ?

ព្រះពោធិសត្វសួរ អ្នកណាជាសាក្សីរបស់អ្នក ?

គ្រានោះ សេនាមារច្រើនសែនកោដិនាំគ្នាពោលព្រមគ្នាថា យើងជាសាក្សី យើងជាសាក្សី ។

ព្រះពោធិសត្វក៏ពោលពីសាក្សីព្រះអង្គថា

បល្លង្កំ មម ភាវាយ    កិមត្ថញ្ញេន សក្ខិនា
កម្បិតា មទ្ទិយា ទានា    សក្ខិ ហោតិ អយំ មហិ ។

បល្ល័ង្កនេះជារបស់យើង យើងនឹងអាងសាក្សីដទៃធ្វើអ្វី
ផែនដីនេះធ្លាប់ញាប់ញ័រមកហើយ ព្រោះការឲ្យទានមទ្រី
រមែងជាសាក្សីបាន ។

អធិប្បាយថា ម្នាលមារមានចិត្តបាប យើងប្រាថ្នាបល្ល័ង្កនេះ ដោយជាអ្នកមិនបានឲ្យទាន មិនបានរក្សាសីល មិនបានធ្វើទុក្ករកិរិយា អស់ច្រើនរាប់ប្រមាណក៏ទេ ។ កាលយើងឲ្យទាន ៧ ដង រហូតដល់ឲ្យនាងមទ្រីទេវីជាទីបុងក្រោយ ក្នុងជាតិជាវេស្សន្តរ ផែនដីនេះកក្រើកញាប់ញ័រអស់ ៧ ដង ។ ឥឡូវនេះ យើងអង្គុយលើអបរាជិតបល្ល័ង្ក ដើម្បីយកជ័យជម្នះ

ដល់សត្វលោកទាំងអស់ ។ ការតទល់ជាមួយមារដែលមានសេនាដ៏ច្រើនយ៉ាងនេះ តើផែនដីដ៏ធំនេះនឹងនៅស្ងៀមប្រងើយដូចម្ដេចកើត ? ។ មារឯងបានឲ្យសេនារបស់ខ្លួនជាសាក្សីកោង ឯផែនដីនេះវិញ ជាអ្នកស្មើដោយយើងនិងអ្នក ។ ផែនដីនេះ ទោះបីមិនមានចិត្ត ក៏អាចធ្វើជាសាក្សីរបស់យើងទាំងពីរបាន ។ គ្រាន់តែព្រះបរមពោធិសត្វពោលត្រឹមប៉ុណ្ណេះ ក៏លាសណ្ដូកព្រះហស្តចេញពីជាយចីវរ ចង្អុលទៅផែនដី ។

ខណៈនោះ ផែនដីដ៏ធំនេះក៏ក្រើករំពើកញាប់ញ័រ មានសំឡេងលាន់ឮកឹកកងពេញអាកាស ផ្គរក៏លាន់ឮឡើង ដូចជាគ្របសង្កត់ភ្នំទាំង ៧ ។ ផ្ទៃចក្កវាឡទាំងអស់ក៏លាន់ឮឡើង ដូចជាភ្លើងឆេះព្រៃ ។

វសវត្តីមារស្ថិតនៅក្នុងរវាងផែនដី និងអាកាស មិនមានអ្វីជ្រកពួន មិនមានអ្វីជាទីពឹង មិនមានអ្វីជាសរណៈ ក៏គ្រវែងអាវុធ ១,០០០ ចោលក្នុងទីនោះ សូម្បីដំរីមេខលា ក៏មិនសំឡឹងមើលបន្តិច ចៀសចេញទៅបាត់។ កាលមារចៀសចេញទៅបាត់ សេនារបស់មារក៏នាំគ្នាបែកខ្ញែកទៅកាន់ស្ថានទេវលោកជាន់វសវត្តីវិញ ។

កាលសេនាមារចៀសចេញពីទីនោះបាត់ទៅ ពួកទេវតាទាំងឡាយជាដើមគិតគ្នាថា **មារស្ស បរាជយោ ជាតោ, សិទ្ធត្ថកុមារស្ស ជយោ ជាតោ, ជយបូជំ ករិស្សាម** មារប្រាកដជាបរាជ័យ មិនខានទេ, សិទ្ធត្ថកុមារប្រាកដជាឈ្នះមារ មកពួកយើងនឹងគ្នាធ្វើនូវជយបូជា ។

ក្នុងកាលណោះ ទេវតាបានស្រែកថ្វាយជ័យទី ១ ពួកនាគទី ២ ពួកគ្រុឌ ទី ៣ ពួកព្រហ្ម ទី ៤ ។ ដូចក្នុងគម្ពីរវិសុទ្ធជនវិលាសិនី អដ្ឋកថាអបទាន ត្រង់ពុទ្ធវគ្គបញ្ញាក់ជាគាថាថា ៖

ជយោ ហិ ពុទ្ធស្ស សិរីមតោ អយំ

មារស្ស ច ចាបិមតោ បរាជយោ

ឧគ្ឃោសយុំ ពោធិមណ្ឌេ បមោទិតា

ជយំ តទា ទេវគណា មហេសិនោ ។

ក្នុងគ្រានោះឯង ពួកទេវតាទាំងឡាយ
ជាអ្នកស្វែងរកគុណធំ មានចិត្តរីករាយ
ក្នុងពោធិមណ្ឌល បានស្រែកថ្វាយជ័យ
ចំពោះព្រះអង្គថា ព្រះពុទ្ធដ៏មានសិរី
ព្រះអង្គទ្រង់ឈ្នះមារហើយ មារមានចិត្ត
បាប ចាញ់ព្រះអង្គហើយ ។

ជយោ ហិ ពុទ្ធស្ស សិរីមតោ អយំ

មារស្ស ច ចាបិមតោ បរាជយោ

ឧគ្ឃោសយុំ ពោធិមណ្ឌេ បមោទិតា

ជយំ តទា នាគគណា មហេសិនោ ។

ក្នុងគ្រានោះឯង ពួកនាគទាំងឡាយ
ជាអ្នកស្វែងរកគុណធំ មានចិត្តរីករាយ
ក្នុងពោធិមណ្ឌល បានស្រែកថ្វាយជ័យ
ចំពោះព្រះអង្គថា ព្រះពុទ្ធដ៏មានសិរី
ព្រះអង្គទ្រង់ឈ្នះមារហើយ មារមានចិត្ត
បាប ចាញ់ព្រះអង្គហើយ ។

ជយោ ហិ ពុទ្ធស្ស សិរីមតោ អយំ

មារស្ស ច បាបិមតោ បរាជយោ

ឧក្កាសយុំ ពោធិមណ្ឌេ បមោទិតា

ជយំ តទា សុបណ្ណសង្ឃាបិ មហេសិនោ។

ក្នុងគ្រានោះឯង ពួកគ្រុឌទាំងឡាយ
ជាអ្នកស្វែងរកគុណធំ មានចិត្តរីករាយ
ក្នុងពោធិមណ្ឌល បានស្រែកថ្វាយជ័យ
ចំពោះព្រះអង្គថា ព្រះពុទ្ធដ៏មានសិរី
ព្រះអង្គទ្រង់ឈ្នះមារហើយ មារមានចិត្ត
បាប ចាញ់ព្រះអង្គហើយ ។

ជយោ ហិ ពុទ្ធស្ស សិរីមតោ អយំ

មារស្ស ច បាបិមតោ បរាជយោ

ឧគ្ឃោសយុំ ពោធិមណ្ឌេ បមោទិតា

ជយំ តទា ព្រហ្មគណា មហេសិនោ ។

*ក្នុងគ្រានោះឯង ពួកព្រហ្មទាំងឡាយ*
*ជាអ្នកស្វែងរកគុណធំ មានចិត្តរីករាយ*
*ក្នុងពោធិមណ្ឌល បានស្រែកថ្វាយជ័យ*
*ចំពោះព្រះអង្គថា ព្រះពុទ្ធដ៏មានសិរី*
*ព្រះអង្គទ្រង់ឈ្នះមារហើយ មារមានចិត្ត*
*បាប ចាញ់ព្រះអង្គហើយ ។*

*ក្នុងរាត្រីបឋមយាមថ្ងៃ ១៥ កើតពេញបូណ៌មី ខែ ពិសាខ ព្រះអង្គទ្រង់សម្រេចនូវបុព្វេនិវាសានុស្សតិញ្ញាណ, មជ្ឈិមយាម ទ្រង់សម្រេចនូវចុតូបបាតញ្ញាណ គឺទិព្វចក្ខុ, ក្នុងបច្ឆិមយាមនៃរាត្រីព្រះអង្គទ្រង់ពិចារណានូវបច្ចយាការៈញុំាងអនាបានចតុត្ថជ្ឈានឲ្យកើតឡើង ធ្វើឈានទោះជាបាទចម្រើនវិបស្សនា ញុំាងកិលេសទាំងពួងឲ្យអស់ទៅដោយមគ្គទី៤ គឺអរហត្តមគ្គ ទ្រង់ចាក់ធ្លុះនូវសព្វញ្ញុតញ្ញាណ ដំណាលគ្នានឹងអរុណរះឡើង ។ ក្នុងខណៈ ដែលព្រះអង្គទ្រង់សម្រេចនូវសព្វញ្ញុតញ្ញាណ ក៏ទ្រង់ព្រះនាមថា* ***សម្មាសម្ពុទ្ធ*** *ក្នុងលោកនេះ ។*

*ក្នុងកាលណោះ លោកធាតុមួយម៉ឺន ក៏មានពន្លឺភ្លឺព្រោងព្រាត។ ផែនដីកម្រើកញាប់ញ័រ រហូតដល់ទឹកជាទីទ្រផែនដី ។ បុព្វនិមិត្ត ៣២ ប្រការ ក៏បានកើតឡើង ។ ។ ព្រះសម្មាសម្ពុទ្ធជាម្ចាស់ ទ្រង់ត្រិះរិះថា យើងរួចផុត*

ចាកសង្សារវដ្តដ៏ធំហើយហ្ន៎ ពុទ្ធភូមិដ៏ធំក្រៃលែងនេះ យើងបានសម្រេចហើយ ជ័យជម្នះដ៏ធំយើងបានធ្វើហើយ ធម្មចក្កដ៏ធំក្រៃលែងយើងបានហើយ ។ ម្យ៉ាងទៀត យើងជាអ្នកសមគួរសម្ដែងធម៌ដល់មហាជន ហើយអាចរំដោះមហាជនឲ្យរួចផុតចាកពន្ធនាគារគឺភព ។ កាលព្រះពុទ្ធជាម្ចាស់ទ្រង់ត្រិះរិះយ៉ាងនេះហើយ បីតិយ៉ាងក្រៃលែងក៏បានកើតឡើង ព្រះអង្គក៏ទ្រង់បន្លឺឧទាន ដោយបីតិថា ៖

អនេកជាតិសំសារំ សន្ធាវិស្សំ អនិព្វិសំ
គហការំ គវេសន្តោ ទុក្ខា ជាតិ បុនប្បុនំ ។
គហការក ទិដ្ឋោសិ បុន គេហំ ន កាហសិ
សព្វា តេ ផាសុកា ភគ្គា គហកូដំ វិសង្ខតំ
វិសង្ខារគតំ ចិត្តំ តណ្ហានំ ខយមជ្ឈគា ។

នៃជាងផ្ទះ អ្នកឯងធ្វើផ្ទះគឺអត្តភាព តថាគតឃើញហើយ
អ្នកនឹងធ្វើផ្ទះ(របស់តថាគត)ទៀត មិនបានឡើយ ឆ្អឹងជំនីរ
គឺកិលេសរបស់អ្នកទាំងអស់ តថាគតកាច់បំបាក់ហើយ
ជំបូលផ្ទះគឺអវិជ្ជា តថាគតកម្ចាត់ចោលហើយ ចិត្តរបស់
តថាគតដល់ព្រះនិព្វានដែលមានសង្ខារប្រាសទៅហើយ
តថាគតបានដល់ធម៌ជាគ្រឿងក្ស័យតណ្ហាទាំងឡាយហើយ។

## សប្តាហ៍ទី ១ បន្ទាប់ពីត្រាស់ដឹង

បន្ទាប់ព្រះសម្មាសម្ពុទ្ធជាម្ចាស់ទ្រង់បន្លឺព្រះឧទានហើយ ព្រះអង្គទ្រង់គង់តែនព្រះភ្នែនចូលសមាបត្តិ សោយវិមុត្តិសុខលើបល្ល័ង្ក ក្រោមដើមសិរីមហាពោធិព្រឹក្សអស់ចំនួន ៧ ថ្ងៃ ដោយព្រះទ័យថា យើងបំពេញបារមីមកអស់ចំនួន ៤ អសង្ខេយ្យ ១ សែនកប្ប ព្រោះអាស្រ័យបល្ល័ង្កនេះ បល្ល័ង្កនេះ ជាវិជយបល្ល័ង្ក ជាមង្គលបល្ល័ង្ករបស់យើង ។

## សប្តាហ៍ទី ២ បន្ទាប់ពីត្រាស់ដឹង

កាលព្រះសម្មាសម្ពុទ្ធ ព្រះអង្គគង់ស្ងៀមក្រោមសិរីមហាពោធិព្រឹក្សអស់មួយសប្តាហ៍យ៉ាងនេះ ។ ពួកទេវតាទាំងឡាយគិតគ្នាថា សិទ្ធត្ថ ទំនងមានកិច្ចដែលត្រូវធ្វើទៀត ទេដឹង! បានជាមិនលះបង់នូវសេចក្តីអាល័យក្នុងបល្ល័ង្កនេះ ។ គ្រានោះ ព្រះសាស្តាដើម្បីនិមន្តកម្ចាត់បង់នូវមន្ទិលសង្ស័យរបស់ទេវតាទាំងឡាយ ទ្រង់និមន្តហោះឡើងអាកាស សម្តែងនូវយមកបាដិហារ្យ ដូចថ្ងៃព្រះអង្គសម្តែងយមកបាដិហារ្យក្នុងក្រុងសាវត្ថី ។ ពេលនោះ ទេវតាទាំងឡាយក៏ប្រាកដក្នុងចិតថា ព្រះសិទ្ធត្ថបានត្រាស់ដឹងជាព្រះពុទ្ធពិតប្រាកដហើយ ។

បន្ទាប់ពីព្រះសម្មាសម្ពុទ្ធទ្រង់សម្តែងនូវយមកបាដិហារ្យហើយ ព្រះអង្គទ្រង់យាងចុះទិសខាងជើង ឈរសំឡឹងមើលបល្ល័ង្ក និងសិរីមហាពោធិព្រឹក្ស ដែលជាទីសម្រេចនូវផលនៃបារមីអស់ចំនួន ៤ អសង្ខេយ្យ ១ សែនកប្ប ដោយព្រះទ័យថា យើងបានសម្រេចហើយនូវសព្វញ្ញុតញ្ញាណ

លើបល្ល័ង្កនេះហ្ន៎ ! ។ ព្រះអង្គទ្រង់ឈរសំឡឹងមើល មិនប៉ប្រិចព្រះនេត្រ អស់ចំនួន ៧ ថ្ងៃ ។ ទីនោះមានឈ្មោះថា **អនិមិសចេតិយ** ។

## សប្តាហ៍ទី ៣ បន្ទាប់ពីត្រាស់ដឹង

បន្ទាប់មកព្រះសម្មាសម្ពុទ្ធព្រះអង្គទ្រង់ចង្ក្រមជិតដើមមហាពោធិព្រឹក្ស ពីទិសខាងកើត ទៅទិសខាងលិចអស់ចំនួន ៧ ថ្ងៃ ។ ទីនោះមានឈ្មោះថា **រតនចង្កមចេតិយ** ។

## សប្តាហ៍ទី ៤ បន្ទាប់ពីត្រាស់ដឹង

ក្នុងសប្តាហ៍ទី ៤ ពួកទេវតាបាននិម្មិតនូវផ្ទះកែវក្នុងទិសពាយព្យ ថ្វាយចំពោះព្រះអង្គ ។ កាលណោះ ព្រះសម្មាសម្ពុទ្ធទ្រង់និមន្តគង់ពែនភ្នែន ពិចារណានូវគម្ពីរព្រះត្រៃបិដក គឺវិនយបិដក សុត្តន្តបិដក អភិធម្មបិដក ។ កាលព្រះអង្គទ្រង់ពិចារណារហូតដល់មហាបដ្ឋាន ក៏មានពន្លឺដ៏ខ្លាំងក្លាចេញពីព្រះវរកាយព្រះអង្គ ភ្លឺព្រោងព្រាតចាក់ធ្លុះរហូតពេញមួយម៉ឺនលោកធាតុ។

## សប្តាហ៍ទី ៥ បន្ទាប់ពីត្រាស់ដឹង

ក្នុងសប្តាហ៍ទី ៥ ព្រះសម្មាសម្ពុទ្ធជាម្ចាស់ ទ្រង់និមន្តទៅគង់ក្រោមដើមអជបាលនិគ្រោធ ជាស្ថានទីដែលព្រះអង្គទ្រង់ទទួលបច្ច័ន្ននាងសុជាតាកាលនៅជាព្រះពោធិសត្វ ។

គ្រានោះឯង មានព្រាហ្មណ៍ម្នាក់ឈ្មោះហុំហុំកជាតិកៈ (មានជាតិជាអ្នកធ្វើនូវសំឡេងគម្រាមថា ហុំហុំ) ចូលទៅគាល់ព្រះដ៏មានព្រះភាគ លុះចូលទៅដល់ហើយ ក៏រីករាយមួយអន្លើដោយព្រះដ៏មានព្រះភាគ លុះធ្វើពាក្យគួរជាទីរីករាយគួរជាទីរលឹកឲ្យសម្រេចហើយក៏ឋិតនៅ ក្នុងកន្លែងដ៏

សមគួរ ។ លុះព្រាហ្មណ៍នោះឋិតនៅក្នុងកន្លែងដ៏សមគួរហើយ ទើបនិយាយពាក្យនេះនឹងព្រះដ៏មានព្រះភាគថា បពិត្រព្រះគោតមដ៏ចំរើន បុគ្គលដែលបានឈ្មោះថា ព្រាហ្មណ៍ ដោយហេតុប៉ុន្មានយ៉ាង ម្យ៉ាងទៀត ធម៌អ្វីខ្លះសម្រាប់ធ្វើបុគ្គលឲ្យជាព្រាហ្មណ៍ ។ គ្រានោះ ព្រះដ៏មានព្រះភាគ ទ្រង់ជ្រាប់ច្បាស់នូវសេចក្ដីនេះហើយ ក៏បន្លឺនូវឧទានគាថានេះក្នុងវេលានោះថា៖

យោ ព្រាហ្មណោ ពាហិតបាបធម្មោ
និហុំហុង្កោ និក្កសាវោ យតត្តោ
វេទន្តគូ វុសិតព្រហ្មចរិយោ
ធម្មេន សោ ព្រហ្មវាទំ វទេយ្យ
យស្សុស្សទា នត្ថិ កុហិញ្ចិ លោកេ។

ព្រាហ្មណ៍ណាមានបាបធម៌បណ្ដេតចោលហើយ
មានសំឡេងគម្រាមថា ហុំហុំ លះចោលហើយ
មានទឹកម្ចត់គឺកាមាទិក្កិលេសលះចោលហើយ មានចិត្តសង្រួមហើយ ចេះចប់នូវវេទ (គឺមគ្គញាណទាំង ៤)
មានមគ្គព្រហ្មចរិយៈនៅរួមហើយ ម្យ៉ាងទៀត
ព្រាហ្មណ៍ណាមិនមានគំនរគឺរាគាទិក្កិលេសក្នុងអារម្មណ៍បន្តិចបន្តួចក្នុងលោកសន្និវាស ព្រាហ្មណ៍នោះគួរនឹងហៅខ្លួនថា ជាព្រាហ្មណ៍ដោយធម៌បាន ។

## សប្តាហ៍ទី ៦ បន្ទាប់ពីត្រាស់ដឹង

លុះ ៧ ថ្ងៃកន្លងហើយ ព្រះដ៏មានព្រះភាគទ្រង់ក្រោកពីម្លប់អជបាលនិគ្រោធព្រឹក្ស យាងចូលទៅកាន់ដើមរាំងអន្ទក់ លុះចូលទៅដល់ហើយទ្រង់គង់ដោយព្រះភ្លែនតែមួយអស់ ៧ ថ្ងៃក្រោមម្លប់រាំងអន្ទក់ សោយវិមុត្តិសុខ (គឺសុខក្នុងផលសមាបត្តិ) ។

សម័យនោះឯង មហាមេឃពុំជួកាល ក៏បណ្តាលឡើងជាភ្លៀង ។ មានភ្លៀងរលឹមអស់ ៧ ថ្ងៃ បណ្តាលឲ្យអាប់ពន្លឺព្រះអាទិត្យដោយអំណាចខ្យល់ត្រជាក់ ។ គ្រានោះ មុចលិន្ទនាគរាជចេញអំពីលំនៅរបស់ខ្លួនហើយពេនព័ទ្ធព្រះកាយព្រះមានព្រះភាគ ៧ ជុំដោយភ្លែន(របស់ខ្លួន) ហើយលើកពពារដ៏ធំបាំងពីខាងលើព្រះសិរស្សព្រះដ៏មានព្រះភាគ ហើយឋិតនៅដោយគិតថា រងាកុំគប្បីបៀតបៀនព្រះដ៏មានព្រះភាគ ក្តៅកុំគប្បីបៀតបៀនព្រះដ៏មានព្រះភាគ សម្ផស្សរបោមមូសខ្យល់កំដៅថ្ងៃពស់តូចពស់ធំក៏កុំគប្បីបៀតបៀនព្រះដ៏មានព្រះភាគ ។ លុះថ្ងៃ៧កន្លងទៅហើយ លំដាប់នោះ មុចលិន្ទនាគរាជដឹងថា ភ្លៀងរាំងហើយ មេឃស្រឡះហើយ ក៏រំសាយភ្លែនចេញចាកព្រះដ៏មានព្រះភាគ ហើយប្រែភេទរបស់ខ្លួននិម្មិតជាភេទមាណព ឈរប្រណម្យអញ្ជលី នមស្ការព្រះដ៏មានព្រះភាគ ពីខាងទីចំពោះព្រះភក្រ្តព្រះអង្គ ។ គ្រានោះ ព្រះដ៏មានព្រះភាគទ្រង់ជ្រាប់សេចក្តីនោះហើយ ក៏បន្លឺនូវឧទានគាថា ក្នុងវេលានោះថា ៖

សុខោ វិវេកោ តុដ្ឋស្ស  សុតធម្មស្ស បស្សតោ
អព្យាបជ្ឈំ សុខំ លោកេ  បាណភូតេសុ សំយមោ។

សុខា វិរាគតា លោកេ កាមានំ សមតិក្កមោ
អស្មិមានស្ស យោ វិនយោ ឯតំ វេ បរមំ សុខំ ។

*សេចក្ដីស្ងាត់ចាកកិលេស របស់បុគ្គលអ្នកត្រេកអរ (ដោយមគ្គញាណ) មានធម៌ប្រាកដហើយ បាន ឃើញធម៌ (ដោយញាណចក្ខុ) ជាគុណឲ្យកើត សេចក្ដីសុខ សេចក្ដីមិនព្យាបាទនឹងសេចក្ដីសង្រួម មិនបៀតបៀនសត្វទាំងឡាយ ក៏ជាគុណឲ្យកើត សេចក្ដីសុខក្នុងលោក សេចក្ដីណាយចាករាគៈនឹង ការប្រព្រឹត្តិកន្លងកាមទាំងឡាយ ជាគុណឲ្យកើត សេចក្ដីសុខក្នុងលោក កិរិយាកំចាត់បង់ នូវអស្មិ មានះ កិរិយាកំចាត់បង់នូវអស្មិមានះនុ៎ះ ជាសុខ យ៉ាងក្រៃលែង ។*

## *សប្ដាហ៍ទី ៧ បន្ទាប់ពីត្រាស់ដឹង*

*លុះ ៧ ថ្ងៃកន្លងទៅហើយ ព្រះដ៏មានជោគទ្រង់ក្រោកចេញចាក សមាធិនោះហើយ យាងចេញពីម្លប់ដើមរាំងអន្ទក់ ហើយយាងចូលទៅ កាន់ដើមរាជាយតនៈគឺដើមកេះ ។ លុះចូលទៅដល់ហើយទ្រង់គង់ដោយ ព្រះភ្លែនតែមួយអស់ ៧ ថ្ងៃ ក្រោមម្លប់ដើមរាជាតនៈ ទ្រង់សោយវិមុត្តិសុខ (គឺសុខក្នុងផលសមាបត្តិ) ។*

សម័យនោះឯង មានពាណិជពីរនាក់ (ជាបងប្អូនបង្កើត) ឈ្មោះ តបុស្សៈ ១ ភល្លិកៈ ១ ជាអ្នកដើរផ្លូវឆ្ងាយ ចេញអំពីឧក្កលជនបទ សំដៅទៅកាន់ប្រទេសនោះ ។ គ្រានោះ មានទេវតាជាញាតិសាលោហិត របស់តបុស្សៈនឹងភល្លិកៈពាណិជ បាននិយាយពាក្យនេះនឹងតបុស្សៈភល្លិកៈពាណិជថា ម្នាលគ្នាយើង ព្រះដ៏មានព្រះភាគអង្គនេះទើបនឹងបានត្រាស់ជាដំបូង ឥឡូវព្រះអង្គគង់នៅក្រោមម្ចប់រាជាយតនៈ(ឯណោះ) អ្នកទាំងឡាយគួរទៅបូជាព្រះដ៏មានព្រះភាគអង្គនោះដោយសត្តុផង់នឹងសត្តុដុំចុះ ការបូជានោះនឹងបានជាប្រយោជន៍ នឹងសេចក្តីសុខដល់អ្នកទាំងឡាយអស់កាលយូរអង្វែង ។ គ្រានោះ តបុស្សៈនឹងភល្លិកៈពាណិជ ក៏នាំយកនូវសត្តុផង់នឹងសត្តុដុំ ចូលទៅរកព្រះដ៏មានព្រះភាគ លុះចូលទៅដល់ហើយ ថ្វាយបង្គំព្រះដ៏មានព្រះភាគ ហើយឋិតនៅក្នុងកន្លែងដ៏សមគួរ ។ លុះតបុស្សៈនឹងភល្លិកៈពាណិជឋិតនៅក្នុងកន្លែងដ៏សមគួរហើយ ទើបពោលពាក្យនេះនឹងព្រះដ៏មានព្រះភាគថា បពិត្រព្រះអង្គដ៏ចំរើន សូមព្រះដ៏មានព្រះភាគទទួលនូវសត្តុផង់នឹងសត្តុដុំរបស់យើងខ្ញុំ ព្រោះថា ការទទួលនឹងបានជាប្រយោជន៍នឹងសេចក្តីសុខ ដល់យើងខ្ញុំទាំងឡាយអស់កាលយូរអង្វែង ។ គ្រានោះ ព្រះដ៏មានព្រះភាគទ្រង់ត្រិះរិះថា ធម្មតាព្រះតថាគតទាំងឡាយមិនដែលទទួល (អាមិសៈ) ផ្ទាល់នឹងដៃឡើយ បើដូច្នោះតើ តថាគតគួរទទួលនូវសត្តុផង់នឹងសត្តុដុំដោយវត្ថុអ្វីហ្ន៎ ។ គ្រានោះមហារាជទាំង៤ ទ្រង់ជ្រាបព្រះតម្រិះរបស់ព្រះដ៏មានព្រះភាគ (ដោយចិត្តរបស់ខ្លួន) ទើបនាំនូវបាត្រថ្មកែវទាំងឡាយ៤ អំពីទិសទាំង៤ បង្អោនចូលមកថ្វាយព្រះដ៏មាន

ព្រះភាគដោយពាក្យថា បពិត្រព្រះអង្គដ៏ចំរើន សូមព្រះដ៏មានព្រះភាគទទួលនូវសដូវផង់នឹងសដូវដុំដោយបាត្រនេះចុះ ។ ព្រះដ៏មានព្រះភាគក៏ទ្រង់ទទួលនូវសដូវផង់នឹងសដូវដុំដោយបាត្រថ្មកែវទាំងឡាយ ដ៏មានតម្លៃច្រើន លុះទទួលស្រេចហើយក៏ទ្រង់សោយ (ក្នុងពេលនោះ) ។ គ្រានោះឯង តបុស្សៈនឹងភល្លិកៈពាណិជបាននិយាយពាក្យនេះនឹងព្រះដ៏មានព្រះភាគថា បពិត្រព្រះដ៏មានព្រះភាគ យើងខ្ញុំទាំងឡាយនេះសូមដល់នូវព្រះដ៏មានព្រះភាគ និងព្រះធម៌ជាទីរឭក សូមព្រះអង្គទ្រង់ជ្រាបនូវយើងខ្ញុំទាំងឡាយថា ជាឧបាសកបានដល់នូវព្រះពុទ្ធ និងព្រះធម៌ជាទីរឭកស្មើដោយជីវិត ក្នុងកាលមានថ្ងៃនេះជាដើមតរៀងទៅ ។ ។ ក៏ឯពាណិជទាំងឡាយនោះបាននាមបញ្ញត្តិថា **ទ្វេវាចិកឧបាសក** ជាដំបូងក្នុងលោក ។

## សហម្បតីព្រហ្ម អារាធនាព្រះពុទ្ធសម្តែងធម៌

លុះ ៧ កន្លងទៅហើយ ព្រះមានជោគទ្រង់ក្រោកចាកសមាធិនោះហើយយាងចេញអំពីក្រោមម្លប់រាជាយតនៈ ហើយយាងចូលទៅកាន់ដើមអជបាលនិគ្រោធវិញ ។ លំដាប់នោះ ព្រះដ៏មានព្រះភាគគង់សម្ងំក្នុងទីស្ងាត់តែមួយព្រះអង្គទើបទ្រង់ព្រះតម្រិះយ៉ាងនេះថា ក៏ធម៌ដែលតថាគតបានត្រាស់ដឹងហើយនេះឯង ជាធម៌ដ៏ជ្រាលជ្រៅ ជាធម៌គឺសត្វឃើញបានដោយកម្រ ជាធម៌គឺសត្វត្រាស់ដឹងបានដោយកម្រ ជាធម៌រម្ងាប់ទុក្ខ ជាធម៌ដ៏ល្អិត ជាធម៌លុះតែអ្នកប្រាជ្ញទើបត្រាស់ដឹងបាន ក៏ឯពពួកសត្វនេះ សុទ្ធតែនៅកំពុងរីករាយក្នុងសេចក្តីអាល័យ កំពុងត្រេកត្រអាលក្នុងសេចក្តីអាល័យ កំពុងស្រើបស្រាលក្នុងសេចក្តីអាល័យ (ចំពោះកាមទាំងឡាយ) ក៏បដិច្ច-

សមុប្បាទធម៌ គឺធម៌ជាបច្ច័យនៃគ្នានឹងគ្នាណា បដិច្ចសមុប្បាទធម៌នោះ ជាហេតុនាំពពួកសត្វនៅរីករាយក្នុងសេចក្ដីអាល័យ នៅស្រើបស្រាល ក្នុងសេចក្ដីអាល័យ ឃើញបានដោយកម្រ ម្យ៉ាងទៀត ធម៌ណាសម្រាប់រម្ងាប់បង់នូវសង្ខារទាំងពួង សម្រាប់លះបោលនូវឧបធិគឺខន្ធនិងកិលេសទាំងអស់ ជាទីអស់ទៅនៃតណ្ហា ជាទីណាយចាករាគៈ ជាទីរលត់នៃទុក្ខ គឺនិព្វាន ធម៌ទាំងអម្បាលនេះ ជាហេតុដែលពពួកសត្វឃើញបានដោយកម្រក្រៃពេក បើទុកជាតថាគតសំដែងធម៌ទៅក៏គង់សត្វទាំងឡាយដទៃ មិនអាចនឹងត្រាស់ដឹងនូវធម៌របស់តថាគតបានឡើយ ព្រោះហេតុនោះ សេចក្ដីលំបាកសេចក្ដីនឿយព្រួយមុខជានឹងមានដល់តថាគត មិនខាន ។ ម្យ៉ាងទៀត ព្រះគាថាទាំងឡាយជាហេតុអស្ចារ្យសមគួរនេះ ព្រះដ៏មានព្រះភាគមិនដែលបានឮក្នុងកាលមុនឡើយ ក៏កើតប្រាកដដល់ព្រះអង្គថា ៖

កិច្ឆេន មេ អធិគតំ ហលំ ទានិ បកាសិតុំ
រាគទោសបរេតេហិ នាយំ ធម្មោ សុសម្ពុធោ ។
បដិសោតគាមឹ និបុណំ គម្ភីរំ ទុទ្ទសំ អណុំ
រាគរត្តា ន ទក្ខន្តិ តមោខន្ធេន អាវុដា ។

ឥឡូវនេះតថាគតគួរសំដែងនូវធម៌ដែលតថាគតបានត្រាស់ដឹង ហើយដោយកម្រ(ទុំះទៅចុះ) ។ ប៉ុន្តែសត្វទាំងឡាយដែល រាគៈទោសៈគ្របសង្កត់ ក៏មិនអាចនឹងត្រាស់ដឹងនូវធម៌នេះបាន ដោយងាយទេ ។ សត្វទាំងឡាយដែលកំពុងត្រេកអរដោយរាគៈ

ដែលគំនរងងឹត (គឺអវិជ្ជា) កំពុងបិទបាំង (យ៉ាងនេះ) មុខជា
នឹងមិនឃើញនូវធម៌ដែលនាំសត្វឲ្យដល់នូវព្រះនិព្វានជាធម៌
ល្អិតច្បាស់ជ្រាលជ្រៅ សត្វឃើញបានដោយកម្រ(ទុំះទេ) ។

កាលដែលព្រះដ៏មានព្រះភាគពិចារឃើញ ដោយន័យថាដែលត្រិះរិះដូច្នេះហើយ ព្រះហឫទ័យដ៏ឱនទៅដើម្បីសេចក្ដីខ្វល់ខ្វាយតិច មិនឱនទៅដើម្បីសំដែងធម៌ឡើយ ។

លំដាប់នោះ សហម្បតិព្រហ្ម ដែលធ្លាប់បួសជាព្រះភិក្ខុ នាមសហកៈ ក្នុងសាសនាព្រះពុទ្ធកស្សបទសពល បានសម្រេចនូវបឋមជ្ឈាន បដិសន្ធិក្នុងព្រហ្មលោក ជាន់បឋមជ្ឈានភូមិ ដឹងនូវសេចក្ដីត្រិះរិះក្នុងព្រះហឫទ័យរបស់ព្រះដ៏មានព្រះភាគដោយចិត្តរបស់ខ្លួនហើយ ទើបរំពឹងត្រិះរិះដូច្នេះថា អើហ្ន៎ ព្រះតថាគតជាអរហន្តសម្មាសម្ពុទ្ធមានព្រះហឫទ័យឱនទៅដើម្បីសេចក្ដីខ្វល់ខ្វាយតិច មិនឱនទៅដើម្បីសំដែងធម៌ (យ៉ាងនេះ) ឱ!សត្វលោកវិនាសតើហ្ន៎ ឱ! សត្វលោកវិនាសតើហ្ន៎ ។

គ្រានោះ សហម្បតិព្រហ្ម ក៏បាត់អំពីព្រហ្មលោក មកប្រាកដក្នុងទីចំពោះព្រះភក្ត្រព្រះដ៏មានព្រះភាគ (ដោយឆាប់ភ្លាម) ប្រៀបដូចបុរសអ្នកមានកម្លាំងលាចេញនូវដើមដៃដែលខ្លួនបត់ចូល ឬបត់ចូលនូវដើមដៃដែលខ្លួនលាចេញ ។ លំដាប់នោះ សហម្បតិព្រហ្មធ្វើសំពត់ឧត្តរាសង្គឆៀងស្មាម្ខាង ហើយលុតចុះនូវមណ្ឌលជង្គង់ខាងស្ដាំលើផែនដី ផ្គុំម្រាមទាំង ១០ ប្រណម្យអញ្ជលី ថ្វាយបង្គំចំពោះត្រង់ព្រះដ៏មានព្រះភាគ ទើបពោលពាក្យនេះនឹងព្រះដ៏មានព្រះភាគថា បពិត្រព្រះអង្គដ៏ចំរើន សូមព្រះដ៏មានព្រះភាគ

សំដែងធម៌ សូមព្រះសុគតសំដែងធម៌ (ដ្បិត) សត្វទាំងឡាយដែលមានធូលី គឺរាគាទិក្កិលេសដ៏ស្រាលស្តើងក្នុងភ្នែក គឺបញ្ញា តែខាងស្តាប់ធម៌ក៏មុខជានឹងសាបសូន្យមិនខាន សត្វទាំងឡាយអ្នកបំរុងនឹងត្រាស់ដឹងនូវធម៌ក៏គង់មានដែរ ។ សហម្បតិព្រហ្មបានពោលពាក្យនេះ(ប៉ុណ្ណោះ) លុះពោលពាក្យនេះហើយ ក៏ពោលពាក្យដទៃទៀតថា ៖

បាតុរហោសិ មគធេសុ បុព្វេ
ធម្មោ អសុទ្ធោ សមលេហិ ចិន្តិតោ។
អបាបុរេតំ អមតស្ស ទ្វារំ
សុណន្តុ ធម្មំ វិមលេនានុពុទ្ធំ។

ពីមុនរៀងមក ធម៌ដែលជនទាំងឡាយអ្នកប្រកដោយមន្ទិលតែងគិត ជាធម៌មិនបរិសុទ្ធទេ កើតប្រាកដហើយក្នុងដែនមគធៈ ។ សូមព្រះអង្គបើកនូវទ្វារនៃព្រះនិព្វានទុំះ សត្វទាំងឡាយប្រុងចាំស្តាប់ធម៌ ដែលព្រះអង្គជាអ្នកប្រាសចាកមន្ទិលទ្រង់ត្រាស់ដឹងតាម (លំអានព្រះពុទ្ធអំពីបូរាណ) ។

សេលេ យថា បព្វតមុទ្ធនិដ្ឋិតោ
យថាបិ បស្សេ ជនតំ សមន្តតោ
តថូបមំ ធម្មយំ សុមេធ
បាសាទមារុយ្ហ សមន្តចក្ខុ

សោកាវតិណ្ណំ ជនតមបេតសោកោ

អវេក្ខស្សុ ជាតិជរាភិភូតំ ។

ប្រៀបដូចជាបុរសអ្នកមានចក្ខុ ឈរនៅលើកំពូលភ្នំដ៏ហើយដោយថ្ម សុទ្ធ ក្រឡេកមើលឃើញប្រជុំជនដោយជុំវិញយ៉ាងណាមិញ បពិត្រព្រះអង្គមានបញ្ញាល្អ មានសមន្តចក្ខុ ព្រះអង្គជាអ្នកមាន សេចក្តីសោកទៅប្រាសហើយ សូមទ្រង់ឡើងកាន់ប្រាសាទ ដ៏ហើយដោយធម៌ពិចារណា មើលនូវប្រជុំជនអ្នកប្រឡំដោយ សេចក្តីសោកដែលជាតិជរាកំពុងគ្របសង្កត់ មានឧបមាដូច្នោះ ដែរ ។

ឧដ្ឋេហិ វីរ វិជិតសង្គាម

សត្ថវាហ អណណ វិចរ លោកេ ។

ទេសស្សុ ភគវា ធម្មំ

អញ្ញាតារោ ភវិស្សន្តិ ។

បពិត្រព្រះអង្គអ្នកមានព្យាយាម អ្នកឈ្នះសង្គ្រាម ហើយជានាយកនៃពួកសត្វ អ្នកមិនជាប់ជំពាក់បំណុលគឺកាម សូមព្រះអង្គក្រោកឡើង សូមទ្រង់ស្តេចទៅក្នុងលោក ។ សូមព្រះដ៏មានព្រះភាគទ្រង់សំដែងធម៌ សត្វទាំងឡាយអ្នក បំរុងនឹងត្រាស់ដឹងនូវធម៌ ក៏គង់មានដែរ ។

ទេសេតុ សុគតោ ធម្មំ    ទេសេតុ អមតំ អបទំ

លោកានមនុកម្បាយ    ធម្មំ ទេសេតុ នាយក ។

*សូមព្រះសុគតសម្តែងធម៌ សូមសម្តែងព្រះនិព្វានឈ្មោះ*

*អមតៈ បពិត្រព្រះនាយក សូមព្រះមានព្រះភាគ សម្តែង*

*ធម៌ ដើម្បីអនុគ្រោះដល់សត្វលោកទាំងឡាយ ។*

*គ្រានោះ ព្រះដ៏មានព្រះភាគទ្រង់ជ្រាបច្បាស់នូវសេចក្តីអារាធនារបស់សហម្បតិព្រហ្មផង ទ្រង់អាស្រ័យនូវសេចក្តីករុណា ចំពោះសត្វទាំងឡាយផង ទើបទ្រង់រមិលមើលនូវសត្វលោកដោយពុទ្ធចក្ខុ ។ ព្រះដ៏មានព្រះភាគកាលទ្រង់រមិលមើលនូវសត្វលោកដោយពុទ្ធចក្ខុ ទ្រង់បានឃើញសត្វទាំងឡាយមានធូលីគឺ រាគាទិក្កិលេសច្រើនក្នុងភ្នែកខ្លះ មានឥន្ទ្រិយរឹងខ្លះ មានឥន្ទ្រិយទន់ខ្លះ មានអាការល្អខ្លះ មានអាការអាក្រក់ខ្លះ ជាសត្វដែលព្រះអង្គគួរឲ្យត្រាស់ដឹងបានដោយងាយខ្លះ ឲ្យត្រាស់ដឹងបានដោយកម្រខ្លះ ជាអ្នកឃើញបរលោកនឹងទោសដោយសភាពគួរខ្លាចខ្លះ ។ សេចក្តីប្រៀបថា មានផ្កាជលជាតិពួកខ្លះគឺផ្កាព្រលិតក្តីផ្កា ឈូកក្រហមក្តី ផ្កាឈូកសក្តី ក្នុងគុម្ពនៃព្រលិតក្តី ក្នុងគុម្ពនៃឈូកក្រហមក្តី ក្នុងគុម្ពនៃឈូកសក្តី តែងកើតឡើងក្នុងទឹក ចំរើនឡើងក្នុងទឹក លូតលាស់ឡើងតាមទឹក លិចនៅក្នុងទឹកនៅឡើយ មានផ្កាជលជាតិពួកខ្លះគឺផ្កាព្រលិតក្តី ផ្កាឈូកក្រហមក្តី ផ្កាឈូកសក្តី តែងកើតឡើងក្នុងទឹក ចំរើនឡើងក្នុងទឹក ឋិតនៅត្រឹមស្មើនឹងទឹក មានផ្កាជលជាតិពួកខ្លះគឺផ្កាព្រលិតក្តី ផ្កាឈូក ក្រហមក្តី ផ្កាឈូកសក្តី*

តែងកើតឡើងក្នុងទឹក ចំរើនឡើងក្នុងទឹក ដុះខ្ពស់ឡើងជាងទឹក មិនជាប់ជំពាក់ដោយទឹក មានឧបមាយ៉ាងណាមិញ ព្រះដ៏មានព្រះភាគកាលទ្រង់រមិលមើលសត្វលោកដោយពុទ្ធចក្ខុ ទ្រង់ឃើញសត្វទាំងឡាយមានធូលីគឺរាគាទិក្កិលេសតិចក្នុងភ្នែកខ្លះ មានធូលីគឺរាគាទិក្កិលេសច្រើនក្នុងភ្នែក ខ្លះមានឥន្ទ្រិយរឹងខ្លះ មានឥន្ទ្រិយទន់ខ្លះ មានអាការល្អខ្លះ មានអាការមិនល្អខ្លះ ជាសត្វដែលព្រះអង្គគួរឲ្យត្រាស់ដឹងបានដោយងាយខ្លះ ឲ្យត្រាស់ដឹងបានដោយកម្រខ្លះ សត្វជំពូកខ្លះឃើញបរលោកនិងទោសដោយសភាពគួរខ្លាចមានឧបមេយ្យដូច្នោះឯង ។ លុះទ្រង់ឃើញហើយ ទើបទ្រង់សំដែងជាបទគាថានឹងសហម្បតិព្រហ្មថា៖

អបារុតា តេសំ អមតស្ស ទ្វារា
យេ សោតវន្តោ បមុញ្ចន្តុ សទ្ធំ
វិហឹសសញ្ញី បគុណំ ន ភាសិ
ធម្មំ បណីតំ មនុជេសុ ព្រហ្មេ ។

ទ្វារនៃព្រះនិព្វានទាំងនោះបើកហើយ សត្វទាំងឡាយ
ណាមានសោតប្បសាទ សត្វទាំងឡាយនោះចូរ
បញ្ចេញនូវសទ្ធាចុះ ។ ម្នាលព្រហ្ម តថាគតសំគាល់
នូវសេចក្តីនឿយលំបាក បានជាមិនសំដែងធម៌
ដ៏ឧត្តម ដែលតថាគតស្ទាត់ហើយចំពោះមនុស្សទាំងឡាយ ។

គ្រានោះ សហម្បតិព្រហ្មគិតថា ខ្ញុំនអញជាបុគ្គលគឺព្រះដ៏មានព្រះភាគ ទ្រង់យល់ព្រមដើម្បីនឹងសំដែងធម៌ហើយ លុះគិតដូច្នេះហើយ ក៏ថ្វាយបង្គំលាព្រះដ៏មានព្រះភាគធ្វើប្រទក្សិណ ហើយក៏បាត់អំពីទីនោះមួយរំពេចទៅ ។

គ្រានោះ ព្រះដ៏មានព្រះភាគ ទ្រង់ត្រិះរិះយ៉ាងនេះថាតថាគតគួរសំដែងធម៌ដល់អ្នកណាជាមុនហ្ន៎ អ្នកណាអាចត្រាស់ដឹងធម៌នេះឆាប់រហ័សបាន ។ លំដាប់នោះ ព្រះដ៏មានព្រះភាគទ្រង់ត្រិះរិះយ៉ាងនេះទៀតថា អាឡារតាបសកាលាមគោត្រនេះជាបណ្ឌិត ជាអ្នកឆ្លៀវឈ្លាសវាងវៃជាអ្នកមានបញ្ញា មានធូលីគឺរាគាទិក្កិលេសតិចក្នុងភ្នែកយូរមកហើយបើដូច្នោះ គួរតថាគតសំដែងធម៌ដល់អាឡារតាបសកាលាមគោត្រជាមុនចុះ តាបសនោះនឹងត្រាស់ដឹងធម៌នេះឆាប់រហ័សបាន ។ គ្រានោះមានទេវតាអង្គមួយ មានរូបមិនប្រាកដក្រាបទូលព្រះដ៏មានព្រះភាគដោយពាក្យថា បពិត្រព្រះអង្គដ៏ចំរើន អាឡារតាបសកាលាមគោត្រធ្វើកាលកិរិយាស្លាប់ទៅ៧ថ្ងៃហើយ ។ ព្រះដ៏មានព្រះភាគក៏ទ្រង់ជ្រាបថា អាឡារតាបសកាលាមគោត្រធ្វើកាលកិរិយាស្លាប់ទៅ៧ថ្ងៃហើយ ។ គ្រានោះព្រះដ៏មានព្រះភាគទ្រង់ព្រះតម្រិះដូច្នេះថា អាឡារតាបសកាលាមគោត្រនុ៎ះមានសេចក្ដីសាបសូន្យធំ ប្រសិនបើតាបសនោះបានស្ដាប់ធម៌នេះ ក៏គប្បីត្រាស់ដឹងធម៌បានមួយរំពេច ។ គ្រានោះព្រះដ៏មានព្រះភាគទ្រង់ព្រះតម្រិះដូច្នេះថា តថាគតសំដែងធម៌ដល់អ្នកណាជាមុនអេះ អ្នកណានឹងត្រាស់ដឹងធម៌នេះ ឆាប់រហ័សបាន ។ ព្រះដ៏មានព្រះភាគក៏ទ្រង់ព្រះតម្រិះក្នុងលំដាប់នោះទៀតថា ឧទ្ទកតាបសរាមបុត្រនេះឯងជាបណ្ឌិតជាអ្នកឆ្លៀវឈ្លាសវាងវៃ ជាអ្នកមានបញ្ញា មានធូលីគឺរាគាទិក្កិលេសតិចក្នុង

ក្អែកយូរណាស់មកហើយ បើដូច្នោះ គួរតថាគតសំដែងធម៌ដល់ ឧទ្ទកតាបសរាមបុត្រនេះជាមុនចុះ តាបសនោះនឹងត្រាស់ដឹងធម៌ នេះឆាប់រហ័សបាន ។ គ្រានោះមានទេវតាអង្គមួយ មានរូបមិនប្រាកដក្រាបទូលព្រះដ៏មានព្រះភាគដោយពាក្យថា បពិត្រព្រះអង្គដ៏ចំរើន ឧទ្ទកតាបសរាមបុត្រធ្វើកាលកិរិយា ស្លាប់អំពីពេលព្រលប់ទៅហើយ ។ ព្រះដ៏មានព្រះភាគក៏ទ្រង់ជ្រាបថា ឧទ្ទកតាបសរាមបុត្រធ្វើកាលកិរិយា ស្លាប់អំពីពេលព្រលប់ទៅហើយដែរ ។ គ្រានោះព្រះដ៏មានព្រះភាគទ្រង់ព្រះតម្រិះដូច្នេះថា ឧទ្ទកតាបសរាមបុត្រមានសេចក្ដីសាបសូន្យធំ ប្រសិនបើតាបសនោះ បានស្ដាប់ធម៌នេះគប្បីត្រាស់ដឹងធម៌បានមួយរំពេច ។ គ្រានោះព្រះដ៏មានព្រះភាគទ្រង់ព្រះតម្រិះដូច្នេះថា តថាគតគួរសំដែងធម៌ដល់អ្នកណាជាមុនហ្ន៎ អ្នកណានឹងត្រាស់ដឹងធម៌នេះឆាប់រហ័សបាន ។ ព្រះដ៏មានព្រះភាគទ្រង់មានព្រះតម្រិះដូច្នេះក្នុងលំដាប់នោះថា បញ្ចវគ្គិយភិក្ខុទាំងឡាយ មានឧបការៈច្រើនដល់តថាគត ព្រោះថាបានបម្រើតថាគតកាលដែលកំពុងបញ្ជូនចិត្តទៅក្នុងព្យាយាម បើដូច្នោះ គួរតថាគត សំដែងដល់បញ្ចវគ្គិយភិក្ខុទាំងឡាយជាមុនចុះ ។ គ្រានោះ ព្រះដ៏មានព្រះភាគទ្រង់មានព្រះតម្រិះដូច្នេះថា ឥឡូវនេះបញ្ចវគ្គិយភិក្ខុទាំងឡាយនៅឯណា ។ លុះព្រះដ៏មានព្រះភាគទ្រង់ឃើញបញ្ចវគ្គិយភិក្ខុទាំងឡាយ នៅក្នុងឥសិបតនមិគទាយវន ទៀបក្រុងពារាណសី ដោយទិព្វចក្ខុដ៏បរិសុទ្ធស្អាតកន្លងលើសចក្ខុរបស់មនុស្ស ។ គ្រានោះព្រះដ៏មានព្រះភាគគង់នៅក្នុងឧរុវេលាប្រទេស តាមសមគួរដល់ព្រះអធ្យាស្រ័យ ទើបទ្រង់យាងទៅកាន់ចារិកសំដៅទៅរកក្រុងពារាណសី ។

មានអាជីវកម្នាក់ ឈ្មោះឧបកៈ បានឃើញព្រះដ៏មានព្រះភាគស្តេចទៅកាន់ផ្លូវឆ្ងាយ ក្នុងចន្លោះនៃគយាប្រទេសផង ក្នុងចន្លោះពោធិព្រឹក្សផង លុះឃើញហើយក៏ពោលពាក្យនេះនឹងព្រះដ៏មានព្រះភាគថា ម្នាលអាវុសោ ឥន្ទ្រិយទាំងឡាយរបស់អ្នកជ្រះថ្លាណាស់ ឆវិវណ្ណ របស់អ្នកក៏បរិសុទ្ធផូរផង់ ម្នាលអាវុសោ អ្នកបួសចំពោះគ្រូណា អ្នកណាជាគ្រូរបស់អ្នក អ្នកពេញចិត្តនឹងធម៌របស់គ្រូណា ។ កាលឧបកាជីវកសួរយ៉ាងនេះហើយ ព្រះដ៏មានព្រះភាគទ្រង់ឆ្លើយតបដោយពាក្យជាគាថាទៅរកឧបកាជីវកថា៖

សព្វាភិភូ សព្វវិទូហមស្មិ

សព្វេសុ ធម្មេសុ អនូបលិត្តោ

សព្វញ្ជហោ តណ្ហាក្ខយេ វិមុត្តោ

សយំ អភិញ្ញាយ កមុទ្ទិសេយ្យំ ។

តថាគតជាអ្នកគ្របសង្កត់នូវតេភូមិកធម៌ទាំងអស់ ត្រាស់ដឹងនូវចតុភូមិកធម៌ទាំងអស់ មិនប្រឡាក់ដោយកិលេសក្នុងតេភូមិកធម៌ទាំងអស់ បានលះបោលនូវតេភូមិកធម៌ទាំងអស់ហើយមានចិត្តផុតស្រឡះហើយ ព្រោះអស់ទៅនៃតណ្ហា ដឹងច្បាស់នូវចតុភូមិកធម៌ដោយខ្លួនឯងចាំបាច់ចំពោះបុគ្គលណា ។

ន មេ អាចរិយោ អត្ថិ　　សទិសោ មេ ន វិជ្ជតិ

សទេវកស្មឹ លោកស្មឹ　　នត្ថិ មេ បដិបុគ្គលោ ។

តថាគតមិនមានអាចារ្យទេ មិនមានបុគ្គលដទៃស្មើនឹង
តថាគតឡើយ ក្នុងលោកនេះព្រមទាំងទេវលោក
មិនមានបុគ្គលប្រៀបផ្ទឹមនឹងតថាគតបានឡើយ ។

អហញ្ហិ អរហា លោកេ អហំ សត្ថា អនុត្តរោ
ឯកោម្ហិ សម្មាសម្ពុទ្ធោ សីតិភូតោស្មិ និព្វុតោ ។

ព្រោះថា តថាគតជាអរហន្តក្នុងលោក ជាសាស្តាខ្ពស់
បំផុត ជាអ្នកត្រាស់ដឹងដោយប្រពៃចំពោះខ្លួនឯង តថា-
គតមានសេចក្តីត្រជាក់ មានភ្លើងកិលេសរលត់ហើយ ។

ធម្មចក្កំ បវត្តេតុំ គច្ឆាមិ កាសិនំ បុរំ
អន្ធីភូតស្មឹ លោកស្មឹ អាហញ្ឆំ អមតទុន្ទុភឹ ។

ឥឡូវតថាគតទៅកាន់ក្រុងនៃពួកជនអ្នកកាសីដើម្បីនឹង
សំដែងធម្មចក្ក ដោយបំណងថា តថាគតនឹងវាយនូវស្គរ
គឺអមតនិព្វានចំពោះសត្វលោក ដែលងងឹតគឺអវិជ្ជាកំពុង
គ្របសង្កត់ ។

ឧបកាជីវកក៏តបថា ម្នាលអាវុសោ អ្នកប្តេជ្ញាខ្លួនអ្នកថាយ៉ាងណាអ្នក
គួរដើម្បីបាននូវឈ្មោះថា អនន្តជិនៈ យ៉ាងនោះឯង ។ ព្រះសម្មាសម្ពុទ្ធ
ទ្រង់មានព្រះពុទ្ធដីកាទៀតថា ៖

មាទិសា វេ ជិនា ហោន្តិ យេ បត្តា អាសវក្ខយំ
ជិតា មេ បាបកា ធម្មា តស្មាហមុបក ជិនោ ។

ជនទាំងឡាយណា បានដល់នូវធម៌ សម្រាប់ធ្វើអាសវៈ
ឲ្យអស់ទៅ ជនទាំងឡាយនោះឈ្មោះថា ជិនៈ ជាអ្នក
ឈ្នះកិលេស ប្រាកដដូចជាតថាគតដែរ ។ តថាគត
បានឈ្នះបាបធម៌ទាំងឡាយហើយ ម្នាលឧបកៈ ព្រោះ
ហេតុនោះ ទើបតថាគតបាននូវឈ្មោះថា ជិនៈ ជាអ្នក
ឈ្នះបាបធម៌ ។

កាលព្រះដ៏មានព្រះភាគទ្រង់មានព្រះពុទ្ធដីកាយ៉ាងនេះហើយ ឧបកាជីវកពោលពាក្យថា ម្នាលអាវុសោ ពាក្យយ៉ាងហ្នឹង ពិតមែនហើយ ថាហើយក៏ងក់ក្បាលហើយកាន់យកផ្លូវខុស គឺដើរបែកផ្លូវគ្នា ចៀសចេញទៅ ។

គ្រានោះ ព្រះដ៏មានព្រះភាគទ្រង់យាងទៅកាន់ចារិកតាមលំដាប់ ហើយក៏យាងចូលទៅក្រុងពារាណសី រួចហើយទ្រង់យាងទៅឯឥសិបតនមិគទាយវន សំដៅទៅរកកន្លែងដែលបញ្ចវគ្គិយភិក្ខុនៅ ។ បញ្ចវគ្គិយភិក្ខុបានឃើញព្រះដ៏មានព្រះភាគយាងមកអំពីចម្ងាយ លុះឃើញហើយក៏ធ្វើប្តេជ្ញាគ្នាថា ម្នាលអាវុសោ សមណគោតមនេះជាអ្នកប្រតិបត្តិដើម្បីល្មោភឃ្លាតចាកព្យាយាមហើយ វិលត្រឡប់ដើម្បីការៈល្មោភឥឡូវនេះលោកនិមន្តមក យើងទាំងអស់គ្នាមិនគួរថ្វាយបង្គំ មិនគួរក្រោកទទួលលោកទេ មិនគួរទទួលយកបាត្រចីវររបស់លោកឡើយ ប៉ុន្តែយើងត្រូវក្រាសអាសនៈបម្រុងទុក បើលោកនឹងចង់គង់ក៏គង់ចុះ ។ ព្រះដ៏មានព្រះភាគយាងចូលទៅរកបញ្ចវគ្គិយភិក្ខុដោយប្រការណាៗ បញ្ចវគ្គិយភិក្ខុទាំងនោះក៏មិនអាច

ដើម្បីឋិតនៅ ក្នុងពាក្យប្ដេជ្ញារបស់ខ្លួន ដោយប្រការនោះៗបានឡើយ ក៏ស្រាប់តែក្រោកទទួលព្រះដ៏មានព្រះភាគ ខ្លះទទួលយកបាត្រចីវររបស់ព្រះអង្គ ខ្លះក្រាលអាសនៈថ្វាយ ខ្លះតម្កល់ទឹកលាងព្រះបាទ យកតាំងសម្រាប់រងព្រះបាទនឹងឈ្នាន់រងព្រះបាទមកថ្វាយ ។ ព្រះដ៏មានព្រះភាគគង់លើអាសនៈដែលបញ្ចវគ្គិយភិក្ខុទាំងឡាយរៀបចំទុកហើយ ។ លុះព្រះដ៏មានព្រះភាគគង់ហើយក៏ទ្រង់លាងព្រះបាទទាំងពីរ ។ ទើបបញ្ចវគ្គិយភិក្ខុហៅព្រះដ៏មានព្រះភាគដោយចំព្រះនាមផង ដោយពាក្យថា អាវុសោផង ។ កាលបញ្ចវគ្គិយភិក្ខុទាំងឡាយ ពោលពាក្យហៅយ៉ាងនេះហើយ ព្រះភគវន្តមុនីទ្រង់មានព្រះពុទ្ធដីកាយ៉ាងនេះនឹងបញ្ចវគ្គិយភិក្ខុទាំងឡាយថា ម្នាលភិក្ខុទាំងឡាយ អ្នកទាំងអស់គ្នា កុំហៅតថាគតដោយចំឈ្មោះនឹងពាក្យថាអាវុសោឡើយ ម្នាលភិក្ខុទាំងឡាយ តថាគតជាអរហន្តសម្មាសម្ពុទ្ធហើយ ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយចូរប្រុងសោតប្បសាទចុះ ឥឡូវតថាគតនឹងប្រៀនប្រដៅនូវអមតធម៌ដែលតថាគតត្រាស់ដឹងហើយ ឥឡូវតថាគតនឹងសំដែងធម៌ ក៏កុលបុត្រទាំងឡាយដែលចេញចាកផ្ទះហើយបួសក្នុងភាពនៃបុគ្គលគ្មានការងារជាប្រយោជន៍ដល់ផ្ទះដោយប្រពៃ ដើម្បីប្រយោជន៍ដល់អនុត្តរធម៌ណា អ្នកទាំងឡាយកាលបើបានប្រតិបត្តិតាមពាក្យប្រដៅរបស់តថាគតហើយ ពុំយូរឡើយមុខជានឹងបានធ្វើឲ្យជាក់ច្បាស់ដោយបញ្ញាខ្លួនឯងក្នុងបច្ចុប្បន្ននេះចំពោះអនុត្តរធម៌នោះ ជាទីបំផុតនៃមគ្គព្រហ្មចរិយៈ នឹងសម្រេចសម្រាន្តនៅដោយឥរិយាបថទាំង ៤ ។ កាលព្រះដ៏មានព្រះភាគទ្រង់មានព្រះពុទ្ធដីកាយ៉ាងនេះហើយ បញ្ចវគ្គិយភិក្ខុក៏ពោលពាក្យនេះនឹង

ព្រះដ៏មានព្រះភាគថា បពិត្រព្រះគោតមដ៏មានអាយុ ព្រះអង្គមិនទាន់បាន ត្រាស់ដឹងនូវឧត្តរិមនុស្សធម្ម ជាធម៌វិសេសដោយញាណ និងទស្សនៈដ៏ ឧត្តមអាចកំចាត់បង់នូវកិលេស ដោយការប្រព្រឹត្តនោះផង ដោយការប្រតិបត្តិ នោះផង ដោយអំពើដែលអ្នកដទៃធ្វើតាមបានដោយកម្រផង ឥឡូវនេះ ព្រះអង្គប្រតិបត្តិដើម្បីល្មោភច្រើនហើយ ឃ្លាតចាកព្យាយាមហើយ វិល ត្រឡប់មកដើម្បីល្មោភច្រើន ហើយក៏នឹងបានត្រាស់ដឹងឧត្តរិមនុស្សធម៌ដ៏ វិសេស ដោយញាណនិងទស្សនៈដ៏ឧត្តមអាចកំចាត់បង់នូវកិលេសដូចម្តេច បាន ។ លុះបញ្ចវគ្គិយភិក្ខុទាំងឡាយពោលពាក្យយ៉ាងនេះហើយ ទើប ព្រះដ៏មានព្រះភាគទ្រង់មានព្រះបន្ទូលយ៉ាងនេះនឹង បញ្ចវគ្គិយភិក្ខុថា ម្នាល ភិក្ខុទាំងឡាយ តថាគតមិនមែនប្រតិបត្តិដើម្បីល្មោភច្រើនទេ មិនឃ្លាតចាក ព្យាយាមទេ មិនវិលត្រឡប់ដើម្បីល្មោភច្រើនដូច្នោះទេ ម្នាលភិក្ខុទាំងឡាយ តថាគតបានជាអរហន្តសម្មាសម្ពុទ្ធហើយ ម្នាលភិក្ខុទាំងឡាយអ្នកទាំងឡាយ ចូរប្រើងសោតប្បសាទចុះ តថាគតនឹងប្រៀនប្រដៅនូវព្រះនិព្វាន ដែលតថាគត បានត្រាស់ដឹងហើយ ឥឡូវតថាគតនឹងសំដែងធម៌ ក៏កុលបុត្រទាំងឡាយ ចេញចាកផ្ទះហើយបួសក្នុងភាពនៃបុគ្គល មិនមានការងារជាប្រយោជន៍ដល់ ផ្ទះដោយប្រពៃដើម្បីការប្រយោជន៍ដែលអនុត្តរធម៌ណា អ្នកទាំងឡាយ កាលបើបានប្រតិបត្តិ គួរដល់ពាក្យប្រដៅរបស់តថាគតហើយ ពុំយូរឡើយ មុខជានឹងបានធ្វើឲ្យជាក់ច្បាស់ដោយប្រាជ្ញាខ្លួនឯង ក្នុងបច្ចុប្បន្ននេះចំពោះ អនុត្តរធម៌នោះជាទីបំផុតនៃមគ្គព្រហ្មចរិយៈ នឹងសម្រេចសម្រាន្តនៅ ដោយ ឥរិយាបថទាំង ៤ ។ បញ្ចវគ្គិយភិក្ខុទាំងឡាយពោលពាក្យនេះនឹងព្រះ

ដ៏មានព្រះភាគជាគំរប់ពីរដងផង ។បេ។ ព្រះដ៏មានព្រះភាគទ្រង់មានព្រះពុទ្ធដីកានេះនឹងបញ្ចវគ្គិយភិក្ខុទាំងឡាយពោលពាក្យនេះ នឹងព្រះដ៏មានព្រះភាគជាគំរប់បីដងទៀតថា បពិត្រព្រះគោតមដ៏មានអាយុ ព្រះអង្គមិនទាន់បានត្រាស់ដឹងនូវឧត្តរិមនុស្សធម៌ ជាធម៌វិសេស ដោយញាណនឹងទស្សនៈដ៏ឧត្តម អាចកំចាត់បង់នូវកិលេស ដោយការប្រព្រឹត្តនោះផង ដោយសេចក្តីប្រតិបត្តិនោះផង ដោយអំពើដែលជនដទៃធ្វើតាមបានដោយកម្រនោះផង ឥឡូវនេះព្រះអង្គប្រតិបត្តិដើម្បីល្មោភច្រើន ឃ្លាតចាកព្យាយាមហើយ វិលត្រឡប់ដើម្បីល្មោភច្រើននឹងបានត្រាស់ដឹងឧត្តរិមនុស្សធម៌ ជាធម៌វិសេស ដោយញាណនឹងទស្សនៈដ៏ឧត្តមអាចកំចាត់បង់នូវកិលេសដូចម្តេចបាន ។ កាលបើបញ្ចវគ្គិយភិក្ខុទាំងឡាយពោលពាក្យយ៉ាងនេះហើយ ព្រះដ៏មានព្រះភាគទ្រង់មានព្រះពុទ្ធដីកានេះនឹងបញ្ចវគ្គិយភិក្ខុទាំងឡាយថា ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយចូរពិចារណាមើលនូវពាក្យ របស់តថាគតឥឡូវនេះដូចគ្នានឹងកាលមុនអំពីកាលឥឡូវនេះដែរឬទេ ។ បញ្ចវគ្គិយភិក្ខុទាំងឡាយតបថា បពិត្រព្រះអង្គដ៏ចំរើន ពាក្យហ្នឹងព្រះអង្គមិនដែលពោលទេ ។ ព្រះអង្គត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតបានជាអរហន្តសម្មាសម្ពុទ្ធហើយ ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយចូរប្រុង សោតប្បសាទចុះតថាគតនឹងប្រៀនប្រដៅព្រះនិព្វាន ដែលតថាគតបានត្រាស់ដឹងហើយ ឥឡូវតថាគតនឹងសំដែងធម៌ ក៏កុលបុត្រទាំងឡាយចេញចាកផ្ទះបួសក្នុងភាពនៃបុគ្គលមិនមានការងារជាប្រយោជន៍ដល់ផ្ទះដោយប្រពៃ ដើម្បីប្រយោជន៍ដល់អនុត្តរធម៌ណា កាលបើអ្នកទាំងឡាយប្រតិបត្តិគួរតាមពាក្យប្រដៅរបស់

តថាគត ពុំយូរឡើយ មុខជានឹងបានធ្វើឲ្យជាក់ច្បាស់ដោយប្រាជ្ញាខ្លួនឯង ក្នុងបច្ចុប្បន្ននេះចំពោះអនុត្តរធម៌នោះ ជាទីបំផុតនៃមគ្គព្រហ្មចរិយៈ ហើយសម្រេចសម្រាន្តនៅដោយឥរិយាបថទាំង ៤ ។ ព្រះដ៏មានព្រះភាគបានញុំាងបញ្ចវគ្គិយភិក្ខុទាំងឡាយឲ្យយល់ច្បាស់ ក្នុងពេលនោះ ។ លុះគ្រាជាខាងក្រោយ បញ្ចវគ្គិយភិក្ខុទាំងឡាយ តាំងចិត្តស្តាប់ព្រះដ៏មានព្រះភាគ ផ្ទៀងនូវសោតប្បសាទហើយ ផ្ចង់ចិត្តដើម្បីដឹងច្បាស់ ។

ព្រះសម្មាសម្ពុទ្ធជាម្ចាស់ ព្រះអង្គទ្រង់សម្តែងបឋមទេសនា គឺធម្មចក្កប្បវត្តនសូត្រ ដូចតទៅ ៖

## ធម្មចក្កប្បវត្តនសូត្រ

ឯវម្មេ សុតំ សូត្រនេះ (ឈ្មោះធម្មចក្កប្បវត្តនសូត្រ) គឺខ្ញុំ (ឈ្មោះអានន្ទ) បានស្តាប់មកហើយ យ៉ាងនេះថា

ឯកំ សមយំ ភគវា ពារាណសិយំ វិហរតិ ឥសិបតនេ មិគទាយេ សម័យមួយ ព្រះដ៏មានព្រះភាគ ទ្រង់គង់នៅក្នុងព្រៃឥសិបតនមិគទាយវ័ន ជិតក្រុងពារាណសី ។

តត្រ ខោ ភគវា បញ្ចវគ្គិយេ ភិក្ខូ អាមន្តេសិ ព្រះដ៏មានព្រះភាគទ្រង់ត្រាស់ហៅនូវបញ្ចវគ្គិយភិក្ខុ[១]ទាំងឡាយ ក្នុងទីនោះឯង (ឲ្យតាំងចិត្តស្តាប់នូវភាសិតនេះថា)

[១] ភិក្ខុមានចំនួន៥រូប គឺឈ្មោះ កោណ្ឌញ្ញៈ១ វប្បៈ១ ភទ្ទិយៈ១ មហានាម១ អស្សជិ១ ។

ទ្វេមេ ភិក្ខវេ អន្តា បព្វជិតេន ន សេវិតព្វា ម្នាលភិក្ខុទាំងឡាយ អន្តធម៌ គឺធម៌ជាផ្លូវប្រតិបត្តិអមខាងដ៏លាមកអាក្រក់ទាំងឡាយពីរប្រការនេះ បព្វជិតមិនគួរសេពគប់ គឺថាមិនគួរប្រព្រឹត្តឡើយ ។

កតមេ ទ្វេ អន្តធម៌ទាំងឡាយពីរយ៉ាងនោះដូចម្តេច ?

យោ ចាយំ កាមេសុ កាមសុខល្លិកានុយោគោ ធម៌ណាដែលប្រកបខ្លួនឲ្យជាប់ជំពាក់ដោយកាម ក្នុងកាមទាំងឡាយ

ហីនោ ជាធម៌ថោកទាប

គម្មោ ជាធម៌របស់អ្នកស្រុក

ពោថុជ្ជនិកោ ជាធម៌របស់បុថុជ្ជន

អនរិយោ មិនមែនជារបស់អរិយបុគ្គលទេ

អនត្ថសញ្ហិតោ មិនប្រកបដោយប្រយោជន៍ឡើយ ។

យោ ចាយំ អត្តកិលមថានុយោគោ ធម៌ណាដែលប្រកបសេចក្តីលំបាកដល់ខ្លួន

ទុក្ខោ ជាហេតុនាំឲ្យលំបាកកាយទទេៗ

អនរិយោ មិនមែនជារបស់អរិយបុគ្គលទេ

អនត្ថសញ្ហិតោ មិនប្រកបដោយប្រយោជន៍ឡើយ ។

ឯតេ តេ ខោ ភិក្ខវេ ឧភោ អន្តេ អនុបគម្ម មជ្ឈិមា បដិបទា តថាគតេន អភិសម្ពុទ្ធា ចក្ខុករណី ញាណករណី ឧបសមាយ អភិញ្ញាយ សម្ពោធាយ និព្វានាយ សំវត្តតិ

*ម្នាលភិក្ខុទាំងឡាយ សេចក្តីប្រតិបត្តិជាកណ្តាលមិនលាយប្រឡំ ដោយអន្តធម៌ទាំងឡាយពីរយ៉ាងនោះឯង ដែលតថាគតបានត្រាស់ដឹងហើយ ជាសេចក្តីប្រតិបត្តិធ្វើឲ្យកើតបញ្ញាចក្ខុ (ភ្នែកគឺប្រាជ្ញា) ធ្វើឲ្យកើតសេចក្តីដឹងច្បាស់ប្រាកដ រមែងប្រព្រឹត្តទៅ ដើម្បីសេចក្តីស្ងប់រម្ងាប់ ដើម្បីសេចក្តីដឹងចំពោះ ដើម្បីសេចក្តីដឹងដោយប្រពៃ ដើម្បីសេចក្តីរំលត់ទុក្ខ ។*

កតមា ច សា ភិក្ខវេ មជ្ឈិមា បដិបទា តថាគតេន អភិសម្ពុទ្ធា ចក្ខុករណី ញាណករណី ឧបសមាយ អភិញ្ញាយ សម្ពោធាយ និព្វានាយ សំវត្តតិ *ម្នាលភិក្ខុទាំងឡាយ ក៏សេចក្តីប្រតិបត្តិជាកណ្តាលដែលតថាគតបានត្រាស់ដឹងហើយ ជាសេចក្តីប្រតិបត្តិធ្វើឲ្យកើតបញ្ញាចក្ខុ ធ្វើឲ្យកើតសេចក្តីដឹងច្បាស់ប្រាកដ រមែងប្រព្រឹត្តទៅ ដើម្បីសេចក្តីស្ងប់រម្ងាប់ ដើម្បីសេចក្តីដឹងចំពោះ ដើម្បីសេចក្តីដឹងដោយប្រពៃ ដើម្បីសេចក្តីរំលត់ទុក្ខនោះ តើដូចម្តេច ?*

អយមេវ អរិយោ អដ្ឋង្គិកោ មគ្គោ *អដ្ឋង្គិកមគ្គ គឺធម៌ដូចជាផ្លូវ មានអង្គ ៨ ដ៏ប្រសើរ នេះឯង (ហៅថាសេចក្តីប្រតិបត្តិជាកណ្តាល)*

សេយ្យថីទំ *អដ្ឋង្គិកមគ្គនោះ ដូម្ដេច?*

សម្មាទិដ្ឋិ *ប្រាជ្ញាយល់ឃើញត្រូវ*

សម្មាសង្កប្បោ *សេចក្តីត្រិះរិះត្រូវ*

សម្មាវាចា *សម្តីត្រូវ*

សម្មាកម្មន្តោ *ការងារត្រូវ*

សម្មាអាជីវោ *កិរិយាចិញ្ចឹមជីវិតត្រូវ*

សម្មាវាយាមោ *ព្យាយាមត្រូវ*

សម្មាសតិ *សេចក្តីរឭកត្រូវ*

សម្មាសមាធិ *កិរិយាតម្កល់ចិត្តឲ្យនឹងត្រូវ*

អយំ ខោ សា ភិក្ខវេ មជ្ឈិមា បដិបទា តថាគតេន អភិសម្ពុទ្ធា ចក្ខុករណី ញាណករណី ឧបសមាយ អភិញ្ញាយ សម្ពោធាយ និព្វានាយ សំវត្តតិ *ម្នាលភិក្ខុទាំងឡាយ អដ្ឋង្គិកមគ្គនេះឯង ដែលហៅថា សេចក្តីប្រតិបត្តិជាកណ្តាល ដែលតថាគតបានត្រាស់ដឹងហើយ ជាសេចក្តីប្រតិបត្តិធ្វើឲ្យកើតបញ្ញាចក្ខុ ធ្វើឲ្យកើតសេចក្តីដឹងច្បាស់ប្រាកដ រមែងប្រព្រឹត្តទៅ ដើម្បីសេចក្តីស្ងប់រម្ងាប់ ដើម្បីសេចក្តីដឹងចំពោះ ដើម្បីសេចក្តីដឹងដោយប្រពៃ ដើម្បីសេចក្តីរលត់ទុក្ខ ។*

ឥទំ ខោ បន ភិក្ខវេ ទុក្ខំ អរិយសច្ចំ ជាតិបិ ទុក្ខា ជរាបិ ទុក្ខា ព្យាធិបិ ទុក្ខោ មរណម្បិ ទុក្ខំ សោកបរិទេវទុក្ខទោមនស្សុ-បាយាសាបិ ទុក្ខា អប្បិយេហិ សម្បយោគោ ទុក្ខោ បិយេហិ វិប្បយោគោ ទុក្ខោ យម្បិច្ឆំ ន លភតិ តម្បិ ទុក្ខំ សង្ខិត្តេន បញ្ចុបាទានក្ខន្ធា ទុក្ខា ។

*ម្នាលភិក្ខុទាំងឡាយ ជាតិ គឺកិរិយាកើតនៃខន្ធ ជាហេតុនាំមកនូវទុក្ខ ជរា គឺកិរិយាចាស់គ្រាំគ្រានៃខន្ធ ក៏ជាហេតុនាំមកនូវទុក្ខ ព្យាធិ គឺជំងឺដំកាត់ទាំងឡាយ ក៏ជាហេតុនាំមកនូវទុក្ខ មរណៈ គឺកិរិយាបែកធ្លាយនៃខន្ធ ក៏ជាហេតុនាំមកនូវទុក្ខ សេចក្ដីសោកខ្សឹកខ្សួល ទុក្ខ ទោមនស្ស និងសេចក្ដីចង្អៀតចង្អល់ចិត្តទាំងឡាយ ក៏ជាហេតុនាំមកនូវទុក្ខ កិរិយាប្រកបដោយសត្វនិងសង្ខារទាំងឡាយដែលមិនជាទីស្រឡាញ់ពេញចិត្ត ក៏ជាហេតុនាំមកនូវទុក្ខ កិរិយាព្រាត់ប្រាសចាកសត្វនិងសង្ខារទាំងឡាយ ដែលជាទីស្រឡាញ់ពេញចិត្ត ក៏ជាហេតុនាំមកនូវទុក្ខ កាលបើចង់បាននូវវត្ថុណាមួយហើយ មិនបាននូវវត្ថុនោះ កិរិយាមិនបាននោះ ក៏ជាហេតុនាំមកនូវទុក្ខ ឧបាទានក្ខន្ធទាំងឡាយ ៥ ដែលតថាគតសម្ដែងហើយដោយបំព្រួញ ក៏ជាហេតុនាំមកនូវទុក្ខ កងទុក្ខមានជាតិជាដើមនេះ ឈ្មោះថាទុក្ខអរិយសច្ច ។*

ឥទំ ខោ បន ភិក្ខវេ ទុក្ខសមុទយោ អរិយសច្ចំ យាយំ តណ្ហា ពោនោព្ភវិកា នន្ទិរាគសហាគតា តត្រ តត្រាភិនន្ទិនី

សេយ្យថីទំ កាមតណ្ហា ភវតណ្ហា វិភវតណ្ហា ម្នាលភិក្ខុទាំងឡាយ តណ្ហាឯណា ដែលរមែងតាក់តែងនូវភពថ្មី ប្រកបដោយតម្រេកដោយអំណាចនៃសេចក្តីត្រេកត្រអាល មានកិរិយារីករាយក្នុងអារម្មណ៍នោះជាប្រក្រតី តណ្ហានោះ ដូម្តេចខ្លះ? (តណ្ហានោះ) គឺកាមតណ្ហា ១ ភវតណ្ហា ១ វិភវតណ្ហា ១ តណ្ហាទាំង ៣ នេះ ឈ្មោះថា ទុក្ខសមុទយអរិយសច្ច ។

ឥទំ ខោ បន ភិក្ខវេ ទុក្ខនិរោធោ អរិយសច្ចំ យោ តស្សាយេវ តណ្ហាយ អសេសវិរាគនិរោធោ ចាគោ បដិនិស្សគ្គោ មុត្តិ អនាលយោ ម្នាលភិក្ខុទាំងឡាយ កិរិយារំលត់បង់នូវតណ្ហានោះ ដោយអរិយមគ្គមិនឲ្យមានសេសសល់ កិរិយាលះបង់នូវតណ្ហានោះ កិរិយារលាស់ចោលនូវតណ្ហានោះ កិរិយារួចផុតចាកតណ្ហានោះ កិរិយាមិនអាល័យក្នុងតណ្ហានោះឯណា កិរិយារំលត់បង់នូវតណ្ហា ដោយអរិយមគ្គមិនឲ្យមានសេសសល់ជាដើមនោះឯង ឈ្មោះថា ទុក្ខនិរោធអរិយសច្ច ។

ឥទំ ខោ បន ភិក្ខវេ ទុក្ខនិរោធគាមិនី បដិបទា អរិយសច្ចំ អយមេវ អរិយោ អដ្ឋង្គិកោ មគ្គោ សេយ្យថីទំ សម្មាទិដ្ឋិ សម្មា-សង្កប្បោ សម្មាវាចា សម្មាកម្មន្តោ សម្មាអាជីវោ សម្មាវាយាមោ សម្មាសតិ សម្មាសមាធិ

ម្នាលភិក្ខុទាំងឡាយ អដ្ឋង្គិកមគ្គ ដ៏ប្រសើរនេះឯង ដូចម្តេចខ្លះ ? គឺប្រាជ្ញាយល់ឃើញត្រូវ សេចក្តីត្រិះរិះត្រូវ សម្តីត្រូវ ការងារត្រូវ កិរិយាចិញ្ចឹមជីវិតត្រូវ ព្យាយាមរឭកត្រូវ កិរិយាតម្កល់ចិត្តឲ្យនឹងត្រូវ អដ្ឋង្គិកមគ្គ ដ៏ប្រសើរនេះឯង ឈ្មោះថា ទុក្ខនិរោធគាមិនីបដិបទាអរិយសច្ច ។

(កាលត្រាស់ទេសនានូវលក្ខណៈនៃអរិយសច្ច ៤ ប្រការដូច្នេះហើយ ទើបត្រាស់ទេសនានូវញាណទាំង ៣ ប្រការ គឺសច្ចញ្ញាណ កិច្ចញ្ញាណ កតញ្ញាណ ឲ្យទូទៅក្នុងអរិយសច្ច ៤ តទៅទៀតថា)

ឥទំ ទុក្ខំ អរិយសច្ចន្តិ មេ ភិក្ខវេ បុព្វេ អននុស្សុតេសុ ធម្មេសុ ចក្ខុំ ឧទបាទិ ញាណំ ឧទបាទិ បញ្ញា ឧទបាទិ វិជ្ជា ឧទបាទិ អាលោកោ ឧទបាទិ ម្នាលភិក្ខុទាំងឡាយ ចក្ខុ[២]កើតឡើងហើយ ញាណ[៣]កើតឡើងហើយ បញ្ញា[៤]កើតឡើងហើយ វិជ្ជា[៥]កើតឡើងហើយ ពន្លឺភ្លឺស្វាង[៦]កើតឡើងហើយដល់តថាគត ក្នុងធម៌ទាំងឡាយ ដែល

---

[២] បញ្ញាដែលឃើញច្បាស់ ។

[៣] បញ្ញាដែលដឹងច្បាស់ ។

[៤] បញ្ញាដែលដឹងមិនខុសមិនក្លាត់ ។

[៥] បញ្ញាដែលកាត់បង់នូវសេចក្តីសង្ស័យ ។

[៦] បញ្ញាដែលកម្ចាត់នូវសេចក្តីងងឹតគឺសេចក្តីល្ងង់ ។

ពីដើម[7]តថាគតមិនធ្លាប់បានឮ បានស្តាប់ថា នេះជាទុក្ខអរិយសច្ច ដូច្នេះឡើយ ។

តំ ខោ បនិទំ ទុក្ខំ អរិយសច្ចំ បរិញ្ញេយ្យន្តិ មេ ភិក្ខវេ បុព្វេ អននុស្សុតេសុ ធម្មេសុ ចក្ខុំ ឧទបាទិ ញាណំ ឧទបាទិ បញ្ញា ឧទបាទិ វិជ្ជា ឧទបាទិ អាលោកោ ឧទបាទិ ចក្ខុកើតឡើងហើយ ញាណកើតឡើងហើយ បញ្ញាកើតឡើងហើយ វិជ្ជាកើតឡើងហើយ ពន្លឺភ្លឺស្វាងកើតឡើងហើយ ដល់តថាគត ក្នុងធម៌ទាំងឡាយ ដែលពីដើមតថាគតមិនធ្លាប់បានឮបានស្តាប់ថា ទុក្ខអរិយសច្ចនេះឯង គួរតែកំណត់ដឹងដោយបញ្ញា ដូច្នេះឡើយ ។

តំ ខោ បនិទំ ទុក្ខំ អរិយសច្ចំ បរិញ្ញាតន្តិ មេ ភិក្ខវេ បុព្វេ អននុស្សុតេសុ ធម្មេសុ ចក្ខុំ ឧទបាទិ ញាណំ ឧទបាទិ បញ្ញា ឧទបាទិ វិជ្ជា ឧទបាទិ អាលោកោ ឧទបាទិ ម្នាលភិក្ខុទាំងឡាយ ចក្ខុកើតឡើងហើយ ញាណកើតឡើងហើយ បញ្ញាកើតឡើងហើយ វិជ្ជាកើតឡើងហើយ ពន្លឺភ្លឺស្វាងកើតឡើងហើយ ដល់តថាគត ក្នុងធម៌ទាំងឡាយ ដែលពីដើមតថាគត មិនធ្លាប់បានឮបានស្តាប់ថា ទុក្ខអរិយសច្ចនេះឯង តថាគតកំណត់ដឹងបានហើយ ដូច្នេះឡើយ ។

[7] ពាក្យថា ពីដើម នេះ ចំពោះយកកាលក្នុងបច្ចិមភពនេះឯងចាប់ផ្តើមតាំងអំពីប្រសូតមក។

ឥទំ ទុក្ខសមុទយោ អរិយសច្ចន្តិ មេ ភិក្ខវេ បុព្វេ អននុស្សុតេសុ ធម្មេសុ ចក្ខុំ ឧទបាទិ ញាណំ ឧទបាទិ បញ្ញា ឧទបាទិ វិជ្ជា ឧទបាទិ អាលោកោ ឧទបាទិ *ម្នាលភិក្ខុទាំងឡាយ ចក្ខុកើតឡើងហើយ ញាណកើតឡើងហើយ បញ្ញាកើតឡើងហើយ វិជ្ជាកើតឡើងហើយ ពន្លឺភ្លឺស្វាងកើតឡើងហើយ ដល់តថាគត ក្នុងធម៌ទាំងឡាយ ដែលពីដើមមកតថាគតមិនធ្លាប់បានឮបានស្តាប់ថា នេះជាទុក្ខសមុទយអរិយសច្ច ដូច្នេះឡើយ ។*

តំ ខោ បនិទំ ទុក្ខសមុទយោ អរិយសច្ចំ បហាតព្វន្តិ មេ ភិក្ខវេ បុព្វេ អននុស្សុតេសុ ធម្មេសុ ចក្ខុំ ឧទបាទិ ញាណំ ឧទបាទិ បញ្ញា ឧទបាទិ វិជ្ជា ឧទបាទិ អាលោកោ ឧទបាទិ *ចក្ខុកើតឡើងហើយ ញាណកើតឡើងហើយ បញ្ញាកើតឡើងហើយ វិជ្ជាកើតឡើងហើយ ពន្លឺភ្លឺស្វាងកើតឡើងហើយ ដល់តថាគត ក្នុងធម៌ទាំងឡាយ ដែលពីដើមតថាគតមិនធ្លាប់បានឮបានស្តាប់ថា ទុក្ខសមុទយអរិយសច្ចនេះឯង គួរតែលះបង់ ដូច្នេះឡើយ ។*

តំ ខោ បនិទំ ទុក្ខសមុទយោ អរិយសច្ចំ បហីនន្តិ មេ ភិក្ខវេ បុព្វេ អននុស្សុតេសុ ធម្មេសុ ចក្ខុំ ឧទបាទិ ញាណំ ឧទបាទិ បញ្ញា ឧទបាទិ វិជ្ជា ឧទបាទិ អាលោកោ ឧទបាទិ *ម្នាលភិក្ខុទាំងឡាយ*

ចក្ខុកើតឡើងហើយ ញាណកើតឡើងហើយ បញ្ញាកើតឡើងហើយ វិជ្ជាកើតឡើងហើយ ពន្លឺភ្លឺស្វាងកើតឡើងហើយ ដល់តថាគត ក្នុងធម៌ទាំងឡាយ ដែលពីដើមតថាគត មិនធ្លាប់បានឮបានស្តាប់ថា ទុក្ខសមុទយអរិយសច្ចនេះឯង តថាគតលះបង់បានហើយ ដូច្នេះឡើយ ។

ឥទំ ទុក្ខនិរោធោ អរិយសច្ចន្តិ មេ ភិក្ខវេ បុព្វេ អននុស្សុតេសុ ធម្មេសុ ចក្ខុំ ឧទបាទិ ញាណំ ឧទបាទិ បញ្ញា ឧទបាទិ វិជ្ជា ឧទបាទិ អាលោកោ ឧទបាទិ ម្នាលភិក្ខុទាំងឡាយ ចក្ខុកើតឡើងហើយ ញាណកើតឡើងហើយ បញ្ញាកើតឡើងហើយ វិជ្ជាកើតឡើងហើយ ពន្លឺភ្លឺស្វាងកើតឡើងហើយ ដល់តថាគត ក្នុងធម៌ទាំងឡាយ ដែលពីដើមតថាគតមិនធ្លាប់បានឮបានស្តាប់ថា នេះជាទុក្ខនិរោធអរិយសច្ច ដូច្នេះឡើយ ។

តំ ខោ បនិទំ ទុក្ខនិរោធោ អរិយសច្ចំ សច្ឆិកាតព្វន្តិ មេ ភិក្ខវេ បុព្វេ អននុស្សុតេសុ ធម្មេសុ ចក្ខុំ ឧទបាទិ ញាណំ ឧទបាទិ បញ្ញា ឧទបាទិ វិជ្ជា ឧទបាទិ អាលោកោ ឧទបាទិ ម្នាលភិក្ខុទាំងឡាយ ចក្ខុកើតឡើងហើយ ញាណកើតឡើងហើយ បញ្ញាកើតឡើងហើយ វិជ្ជាកើតឡើងហើយ ពន្លឺភ្លឺស្វាងកើតឡើងហើយ ដល់តថាគត ក្នុងធម៌ទាំងឡាយ ដែលពីដើម តថាគតមិនធ្លាប់បានឮបានស្តាប់ថា ទុក្ខនិរោធអរិយសច្ចនេះឯង គួរតែធ្វើ ឲ្យជាក់ច្បាស់ ដូច្នេះឡើយ ។

តំ ខោ បនិទំ ទុក្ខនិរោធោ អរិយសច្ចំ សច្ឆិកាតព្វន្តិ មេ ភិក្ខវេ បុព្វេ អននុស្សុតេសុ ធម្មេសុ ចក្ខុំ ឧទបាទិ ញាណំ ឧទបាទិ បញ្ញា ឧទបាទិ វិជ្ជា ឧទបាទិ អាលោកោ ឧទបាទិ *ម្នាលភិក្ខុទាំងឡាយ ចក្ខុកើតឡើងហើយ ញាណកើតឡើងហើយ បញ្ញាកើតឡើងហើយ វិជ្ជាកើតឡើងហើយ ពន្លឺភ្លឺស្វាងកើតឡើងហើយ ដល់តថាគត ក្នុងធម៌ទាំងឡាយដែលពីដើមតថាគត មិនធ្លាប់បានឮបានស្តាប់ថា ទុក្ខនិរោធអរិយសច្ចនេះឯង តថាគតធ្វើឲ្យជាក់ច្បាស់បានហើយ ដូច្នេះឡើយ ។*

ឥទំ ទុក្ខនិរោធគាមិនី បដិបទា អរិយសច្ចន្តិ មេ ភិក្ខវេ បុព្វេ អននុស្សុតេសុ ធម្មេសុ ចក្ខុំ ឧទបាទិ ញាណំ ឧទបាទិ បញ្ញា ឧទបាទិ វិជ្ជា ឧទបាទិ អាលោកោ ឧទបាទិ *ម្នាលភិក្ខុទាំងឡាយ ចក្ខុកើតឡើងហើយ ញាណកើតឡើងហើយ បញ្ញាកើតឡើងហើយ វិជ្ជាកើតឡើងហើយ ពន្លឺភ្លឺស្វាងកើតឡើងហើយ ដល់តថាគត ក្នុងធម៌ទាំងឡាយដែលពីដើមតថាគតមិនធ្លាប់បានឮ បានស្តាប់ថា នេះជាទុក្ខនិរោធគាមិនីបដិបទាអរិយសច្ច ដូច្នេះឡើយ ។*

តំ ខោ បនិទំ ទុក្ខនិរោធគាមិនី បដិបទា អរិយសច្ចំ ភាវេតព្វន្តិ មេ ភិក្ខវេ បុព្វេ អននុស្សុតេសុ ធម្មេសុ ចក្ខុំ ឧទបាទិ ញាណំ ឧទបាទិ បញ្ញា ឧទបាទិ វិជ្ជា ឧទបាទិ អាលោកោ

ឧទចាទិ ម្នាលភិក្ខុទាំងឡាយ ចក្ខុកើតឡើងហើយ ញាណកើតឡើងហើយ បញ្ញាកើតឡើងហើយ វិជ្ជាកើតឡើងហើយ ពន្លឺភ្លឺស្វាងកើតឡើងហើយ ដល់តថាគត ក្នុងធម៌ទាំងឡាយ ដែលពីដើមតថាគតមិនធ្លាប់បានឮបាន ស្តាប់ថា ទុក្ខនិរោធគាមិនីបដិបទាអរិយសច្ចនេះឯង គួរតែចម្រើនឲ្យកើតឡើង ដូច្នេះឡើយ។

តំ ខោ បនិធំ ទុក្ខនិរោធគាមិនី បដិបទា អរិយសច្ចំ ភាវិតន្តិ មេ ភិក្ខវេ បុព្វេ អននុស្សុតេសុ ធម្មេសុ ចក្ខុំ ឧទចាទិ ញាណំ ឧទចាទិ បញ្ញា ឧទចាទិ វិជ្ជា ឧទចាទិ អាលោកោ ឧទចាទិ ម្នាលភិក្ខុទាំងឡាយ ចក្ខុកើតឡើងហើយ ញាណកើតឡើងហើយ បញ្ញាកើតឡើងហើយ វិជ្ជាកើតឡើងហើយ ពន្លឺភ្លឺស្វាងកើតឡើងហើយ ដល់តថាគត ក្នុងធម៌ទាំងឡាយ ដែលពីដើមតថាគត មិនធ្លាប់បានឮបាន ស្តាប់ថា ទុក្ខនិរោធគាមិនីបដិបទាអរិយសច្ចនេះឯង តថាគតចម្រើនឲ្យកើតឡើងបានហើយ ដូច្នេះឡើយ ។

យាវកីវញ្ច មេ ភិក្ខវេ ឥមេសុ ចតូសុ អរិយសច្ចេសុ ឯវន្តិបរិវដ្តំ ទ្វាទសាការំ យថាភូតំ ញាណទស្សនំ ន សុវិសុទ្ធំ អហោសិ ម្នាលភិក្ខុទាំងឡាយ ប្រាជ្ញាដែលដឹងច្បាស់ ឃើញច្បាស់តាមពិត មានបរិវដ្ដៈ[៨]៣ មានអាការៈ[៩]១២ យ៉ាងនេះ(ប្រព្រឹត្តទៅ) ក្នុង

---

[៨] បរិវដ្ដៈ៣ គឺសច្ចញ្ញាណ១ កិច្ចញ្ញាណ១ កតញ្ញាណ១ ។

អរិយសច្ចទាំងឡាយ ៤ នៅមិនទាន់បរិសុទ្ធល្អ មានដល់តថាគត អស់កាលត្រឹមណា ។

នេវ តាវាហំ ភិក្ខវេ សទេវកេ លោកេ សមារកេ សព្រហ្មកេ សស្សមណព្រាហ្មណិយា បជាយ សទេវមនុស្សាយ អនុត្តរំ សម្មាសម្ពោធឹ អភិសម្ពុទ្ធោ បច្ចញ្ញាសឹ ម្នាលភិក្ខុទាំងឡាយ តថាគតក៏មិនទាន់ប្តេជ្ញាខ្លួនថា ជាអ្នកត្រាស់ដឹងនូវសម្មាសម្ពោធិញ្ញាណ ឥតមានសេចក្តីដឹងឯទៀតក្រៃលែងជាងក្នុងលោកព្រមទាំងទេវលោក មារលោក ព្រហ្មលោក ក្នុងពពួកសត្វព្រមទាំងសមណព្រាហ្មណ៍ ព្រមទាំងមនុស្សជាសម្មតិទេព និងមនុស្សដ៏សេស អស់កាលត្រឹមណោះ នៅឡើយទេ ។

យតោ ច ខោ មេ ភិក្ខវេ ឥមេសុ ចតូសុ អរិយសច្ចេសុ ឯវន្តិបរិវដ្ដំ ទ្វាទសាការំ យថាភូតំ ញាណទស្សនំ សុវិសុទ្ធំ អហោសិ ម្នាលភិក្ខុទាំងឡាយ ក៏បញ្ញាដែលដឹងច្បាស់ ឃើញច្បាស់តាមពិត មានបរិវដ្តៈ៣ មានអាការៈ១២ យ៉ាងនេះ (ប្រព្រឹត្តទៅ) ក្នុងអរិយសច្ចទាំងឡាយ៤នេះ បរិសុទ្ធល្អ មានដល់តថាគត ក្នុងកាលឯណា ។

[៩]បរិវដ្តៈ៣នោះឯងវិលទៅដូចជាចក្រ ក្នុងសច្ចៈទាំង៤ គឺក្នុងទុក្ខសច្ច៣ ទុក្ខសមុទយសច្ច៣ ទុក្ខនិរោធសច្ច៣ ទុក្ខនិរោធគាមិនីបដិបទាអរិយសច្ច៣ ផ្សំគ្នាជា១២ ហៅថា អាការៈ ១២។

អថាហំ ភិក្ខវេ សទេវកេ លោកេ សមារកេ សព្រហ្មកេ សស្សមណព្រាហ្មណិយា បជាយ សទេវមនុស្សាយ អនុត្តរំ សម្មាសម្ពោធឹ អភិសម្ពុទ្ធោ បច្ចញ្ញាសឹ

*ម្នាលភិក្ខុទាំងឡាយ តថាគតប្តេជ្ញាខ្លួនថា ជាអ្នកត្រាស់ដឹងនូវសម្មាសម្ពោធិញ្ញាណឥតមានសេចក្តីដឹងឯទៀតក្រៃលែងជាង ក្នុងលោក ព្រមទាំងទេវលោក មារលោក ព្រហ្មលោក ក្នុងពពួកសត្វ ព្រមទាំងសមណព្រាហ្មណ៍ ព្រមទាំងមនុស្សជាសម្មតិទេព និងមនុស្សដ៏សេសក្នុងកាលណោះឯង ។*

ញាណញ្ច បន មេ ទស្សនំ ឧទបាទិ អកុប្បា មេ វិមុត្តិ អយមន្តិមា ជាតិ នត្ថិទានិ បុនព្ភវោតិ *ក៏បញ្ញាដែលដឹងច្បាស់ឃើញច្បាស់ កើតឡើងហើយ ដល់តថាគត ដូច្នេះថា សេចក្តីរួចផុតវិសេសរបស់តថាគត មិនប្រែត្រឡប់កម្រើកទៀតឡើយ ជាតិនេះ ក៏ជាទីបំផុតត្រឹមនេះហើយ ឥឡូវនេះ ភពថ្មី គឺការត្រឡប់កើតទៀត ក៏មិនមានឡើយ ។*

ឥទមវោច ភគវា *ព្រះដ៏មានព្រះភាគ បានត្រាស់ទេសនាព្រះធម្ម-ចក្កប្បវត្តនសូត្រនេះ (ចប់ហើយ)*

អត្តមនា បញ្ចវគ្គិយា ភិក្ខូ ភគវតោ ភាសិតំ អភិនន្ទុន្តិ បញ្ចវគ្គិយភិក្ខុទាំងឡាយ ក៏មានចិត្តត្រេកអររីករាយនឹងភាសិតរបស់ ព្រះដ៏មានព្រះភាគដោយក្រៃពេក ។

ឥមស្មិញ្ច បន វេយ្យាករណស្មឹ ភញ្ញមានេ អាយស្មតោ កោណ្ឌញ្ញស្ស វិរជំ វីតមលំ ធម្មចក្ខុំ ឧទចាទិ

នាកាលវេយ្យាករណ៍ គឺព្រះសូត្រដែលឥតមានគាថានេះ ដែលព្រះដ៏មានព្រះភាគកំពុងត្រាស់ទេសនា ធម្មចក្ខុគឺសោតាបត្តិមគ្គ ដ៏ប្រាសចាកធូលីគឺរាគៈ ប្រាសចាកមន្ទិលគឺអកុសលកើតឡើងហើយ ដល់ព្រះកោណ្ឌញ្ញៈដ៏មានអាយុថា

យំកិញ្ចិ សមុទយធម្មំ សព្វន្តំ និរោធធម្មន្តិ ធម្មជាតណាមួយមានកិរិយាកើតឡើងជាធម្មតា ធម្មជាតនោះទាំងអស់មានកិរិយារលត់ទៅជាធម្មតា ។

បវត្តិតេ ច ភគវតា ធម្មចក្កេ ក៏នាកាលព្រះធម្មចក្កប្បវត្តនសូត្រ គឺព្រះដ៏មានព្រះភាគ ទ្រង់ត្រាស់ទេសនាចប់ហើយ

ភុម្មា ទេវា សទ្ទមនុស្សាវេសុំ ឯតំ ភគវតា ពារាណសិយំ ឥសិបតនេ មិគទាយេ អនុត្តរំ ធម្មចក្កំ បវត្តិតំ អប្បដិវត្តិយំ សមណេន វា ព្រាហ្មណេន វា ទេវេន វា មារេន វា ព្រហ្មុនា វា

កេនចិ វា លោកស្មិន្តិ ភុម្មទេវតាទាំងឡាយ ក៏ញុំាងសំឡេងឲ្យលាន់ឮឡើងដូច្នេះថា ចក្រគឺធម៌នេះ ឥតមានចក្រឯណាមួយក្រៃលែងជាង គឺ សមណៈក្តី ព្រាហ្មណ៍ក្តី ទេវតាក្តី មារក្តី ព្រហ្មក្តី អ្នកឯណានីមួយក្តី ក្នុងលោកសម្តែងពុំបានឡើយ មានតែព្រះដ៏មានព្រះភាគ ព្រះអង្គត្រាស់សម្តែងហើយ ក្នុងឥសិបតនមិគទាយវ័ន ជិតក្រុងពារាណសី ។

ភុម្មានំ ទេវានំ សទ្ទំ សុត្វា ចាតុម្មហារាជិកា ទេវា សទ្ទមនុស្សាវេសុំ ទេវតាទាំងឡាយក្នុងជាន់ចាតុម្មហារាជ បានឮសំឡេងនៃភុម្មទេវតាទាំងឡាយហើយ ក៏ញុំាងសំឡេងឲ្យលាន់ឮឡើង (ដោយសេចក្តីសរសើរដូចគ្នា) ។

ចាតុម្មហារាជិកានំ ទេវានំ សទ្ទំ សុត្វា តាវត្តិំសា ទេវា សទ្ទមនុស្សាវេសុំ ទេវតាទាំងឡាយក្នុងជាន់តាវត្តិង្ស បានឮសំឡេងនៃទេវតាក្នុងជាន់ចាតុម្មហារាជហើយ ក៏ញុំាងសំឡេងឲ្យលាន់ឮឡើង (ដោយសេចក្តីសរសើរដូចគ្នា) ។

តាវត្តិំសានំ ទេវានំ សទ្ទំ សុត្វា យាមា ទេវា សទ្ទមនុស្សាវេសុំ ទេវតាទាំងឡាយក្នុងជាន់យាមា បានឮសំឡេងនៃទេវតាក្នុងជាន់តាវត្តិង្សហើយ ក៏ញុំាងសំឡេងឲ្យលាន់ឮឡើង (ដោយសេចក្តីសរសើរដូចគ្នា) ។

យាមានំ ទេវានំ សទ្ទំ សុត្វា តុសិតា ទេវា សទ្ទមនុស្សាវេសុំ *ទេវតាទាំងឡាយក្នុងជាន់តុសិតបានឮសំឡេងនៃទេវតាក្នុងជាន់យាមាហើយ ក៏ញុំាងសំឡេងឲ្យលាន់ឮឡើង (ដោយសេចក្ដីសរសើរដូចគ្នា)* ។

តុសិតានំ ទេវានំ សទ្ទំ សុត្វា និម្មានរតី ទេវា សទ្ទមនុស្សាវេសុំ *ទេវតាទាំងឡាយក្នុងជាន់និម្មានរតី បានឮសំឡេងនៃទេវតាក្នុងជាន់តុសិតហើយ ក៏ញុំាងសំឡេងឲ្យលាន់ឮឡើង (ដោយសេចក្ដីសរសើរដូចគ្នា)* ។

និម្មានរតីនំ ទេវានំ សទ្ទំ សុត្វា បរនិម្មិតវសវត្តី ទេវា សទ្ទមនុស្សាវេសុំ *ទេវតាទាំងឡាយក្នុងជាន់បរនិម្មិតវសវត្តីបានឮសំឡេងនៃទេវតាក្នុងជាន់និម្មានរតីហើយ ក៏ញុំាងសំឡេងឲ្យលាន់ឮឡើង (ដោយសេចក្ដីសរសើរដូចគ្នា)* ។

បរនិម្មិតវសវត្តីនំ ទេវានំ សទ្ទំ សុត្វា ព្រហ្មកាយិកា ទេវា សទ្ទមនុស្សាវេសុំ ឯតំ ភគវតា ពារាណសិយំ ឥសិបតនេ មិគទាយេ អនុត្តរំ ធម្មចក្កំ បវត្តិតំ អប្បដិវត្តិយំ សមណេន វា ព្រាហ្មណេន វា ទេវេន វា មារេន វា ព្រហ្មុនា វា កេនចិ វា

លោកស្មិន្តិ *ទេវតាទាំងឡាយក្នុងពួកព្រហ្ម បានឮសំឡេងនៃទេវតាក្នុងជាន់ បរនិម្មិតវសវត្តីហើយ ក៏ញ៉ាំងសំឡេងឲ្យលាន់ឮឡើង ដូច្នេះថា ចក្រគឺធម៌នេះ ឥតមានចក្រឯណាមួយក្រៃលែងជាង គឺសមណៈក្តី ព្រាហ្មណ៍ក្តី ទេវតាក្តី មារក្តី ព្រហ្មក្តី អ្នកឯណានីមួយក្តី ក្នុងលោក សម្តែងពុំបានឡើយ មានតែព្រះដ៏មានព្រះភាគព្រះអង្គត្រាស់សម្តែងហើយ ក្នុងឥសិបតនមិគទាយវ័ន ជិតក្រុងពារាណសី ។*

ឥតិហ តេន ខណេន តេន មុហុត្តេន យាវ ព្រហ្មលោកា សទ្ទោ អព្ភុគ្គច្ឆិ *សំឡេងសាធុការលាន់ឮឡើងទៅដរាបដល់ព្រហ្មលោក ក្នុងខណៈនោះ ក្នុងមួយរំពេចនោះ ដោយអាការៈលាន់ឮតៗគ្នាដូច្នេះ ។*

អយញ្ច ទសសហស្សី លោកធាតុ សង្កម្បិ សម្បកម្បិ សម្បវេធិ *ទាំងម៉ឺនលោកធាតុនេះ ក៏កក្រើកញាប់ញ័រ ទាំងខាងលើទាំងខាងក្រោម និងញាប់ញ័រក្នុងទិសទាំងពួង។*

អប្បមាណោ ច ឧឡារោ ឱភាសោ លោកេ បាតុរហោសិ អតិក្កម្ម ទេវានំ ទេវានុភាវន្តិ *ទាំងរស្មីដ៏រុងរឿងក្រៃពេក នឹងប្រមាណមិនបានកន្លងលើសទេវានុភាព នៃទេវតាទាំងឡាយក៏កើតឡើងប្រាកដក្នុងលោក ។*

អថខោ ភគវា ឧទានំ ឧទានេសិ អញ្ញាសិ វត ភោ កោណ្ឌញ្ញោ អញ្ញាសិ វត ភោ កោណ្ឌញ្ញោតិ ។

*លំដាប់នោះ ព្រះដ៏មានព្រះភាគជាម្ចាស់ទ្រង់បន្លឺនូវឧទានវាចាថា ឱ! កោណ្ឌញ្ញៈបានចេះដឹងហើយហ្ន៎ ឱកោណ្ឌញ្ញៈបានចេះដឹងហើយហ្ន៎ ។*

ឥតិហិទំ អាយស្មតោ កោណ្ឌញ្ញស្ស អញ្ញាកោណ្ឌញ្ញោត្វេវ នាមំ អហោសីតិ *ព្រោះហេតុនោះ ពាក្យថាអញ្ញាកោណ្ឌញ្ញៈនេះឯង បានមកជាឈ្មោះកោណ្ឌញ្ញៈដ៏មានអាយុ ។*

*ព្រះធម្មចក្កប្បវត្តនសូត្រ ចប់ ។*

# ធម្មចក្កប្បវត្តនសុត្តវណ្ណនា

ទុតិយស្ស បឋមេ **ពារាណសិយ**ន្តិ ឯវំនាមកេ នគរេ ។ *ពាក្យថា **ក្រុងពារាណសី** បានដល់ ទីក្រុងដែលមានឈ្មោះយ៉ាងនោះ ។* **ឥសិបតនេ មិគទាយេ**តិ ឥសីនំ បតនុប្បតនវសេន ឯវំលទ្ធនាមេ មិគានំ អភយទានវសេន ទិន្នត្តា មិគទាយសង្ខាតេ អារាមេ។ ឯត្ថ ហិ ឧប្បន្នុប្បន្នា សព្វញ្ញុឥសយោ បតន្តិ, ធម្មចក្កប្បវត្តនត្ថំ និសីទន្តីតិ អត្ថោ ។ *ពាក្យថា **ឥសិបតនមិគទាយវន** បានដល់ ក្នុងព្រៃដែលមានឈ្មោះ យ៉ាងនេះ ដោយអំណាចការធ្លាក់ចុះនៃឥសីទាំងឡាយ ។ ក្នុងអារាមពោល គឺព្រៃដែលមានឈ្មោះ **មិគទាយ** ព្រោះឲ្យអភ័យដល់ម្រឹគទាំងឡាយ ដោយអំណាចការឲ្យអភ័យ ។ អធិប្បាយថា ឥសីទាំងឡាយដែលជាសព្វញ្ញូ ជាព្រះបច្ចេកពុទ្ធ រមែងធ្លាក់ចុះ គឺគង់ក្នុងនោះ ដើម្បីញ៉ាំងធម្មចក្កឲ្យប្រព្រឹត្តទៅ ។* នន្ទមូលកបព្ភារតោ សត្តាហច្ចយេន និរោធ-សមាបត្តិតោ វុដ្ឋិតា អនោតត្តទហេ កតមុខធោវនាទិកិច្ចា អាកាសេន អាគន្ត្វា បច្ចេកពុទ្ធឥសយោបេត្ថ ឱតរណវសេន បតន្តិ, ឧបោសថត្ថញ្ច អនុបោសថត្ថញ្ច សន្និបតន្តិ, គន្ធមាទនំ បដិគច្ឆន្តាបិ តតោវ ឧប្បតន្តីតិ ឥមិនា ឥសីនំ បតនុប្បតនវសេន តំ

*“ឥសិបតន”ន្តិ វុច្ចតិ ។ សូម្បីឥសីជាព្រះបច្ចេកពុទ្ធទាំងឡាយ និមន្តចូលនិរោធសមាបត្តិ អស់ ៧ ថ្ងៃ ហើយចេញចាកសមាបត្តិ ធ្វើកិច្ចមានការលុបព្រះភ័ក្ត្រជាដើម ត្រង់អនោតត្តស្រះ និមន្តចេញពីញកភ្នំនន្ទមូលក៍ មកតាមអាកាស រមែងនិមន្តចុះត្រង់ព្រៃនោះ ប្រជុំធ្វើឧបោសថ និងអនុបោសថ, សូម្បីនិមន្តទៅភ្នំ គន្ធមាទន៍ តែងនិមន្តហោះចេញពីព្រៃនោះ និមន្តចេញមកពីភ្នំគន្ធមាទន៍នោះ និមន្តតែងតែធ្លាក់ចុះក្នុងព្រៃនោះវិញ តាមពាក្យដែលពោលមកហើយនេះឯង ព្រៃនោះទើបហៅថា* ***ឥសិបតនៈ*** *ដោយការធ្លាក់ចុះ និងការហោះឡើង នៃឥសីទាំងឡាយ ។*

**អាមណ្ឌសី**តិ ទីបង្ករបាទមូលេ កតាភិនីហារតោ បដ្ឋាយ បារមិយោ បូរេន្តោ អនុបុព្វេន បច្ឆិមភវេ កតាភិនិក្ខមនោ អនុបុព្វេន ពោធិមណ្ឌំ បត្វា តត្ថ អបរាជិតបល្លង្កេ និសិន្នោ មារពលំ ភិន្ទិត្វា បឋមយាមេ បុព្វេនិវាសំ អនុស្សរិត្វា មជ្ឈិមយាមេ ទិព្វចក្ខុំ វិសោធេត្វា បច្ឆិមយាមាវសានេ ទសសហស្សិលោកធាតុំ ឧន្នាទេន្តោ សព្វញ្ញុតំ បត្វា សត្ត សត្តាហានិ ពោធិមណ្ឌេ វីតិនាមេត្វា មហាព្រហ្មុនា អាយាចិតធម្មទេសនោ ពុទ្ធចក្ខុនា លោកំ វោលោកេត្វា លោកានុគ្គហេន ពារាណសឹ គន្ត្វា បញ្ចវគ្គិយេ សញ្ញាបេត្វា

ធម្មចក្កំ បវត្តេតុកាមោ អាមន្តេសិ។

*ពាក្យថា **អាមន្តេសិ** សេចក្តីថា បំពេញបារមី ចាប់ផ្តើមតាំងពីធ្វើអភិនីហារ ទៀបយុគលបាទនៃព្រះពុទ្ធទីបង្ករ និងចេញសាងផ្នួសក្នុងព្រះជាតិចុងក្រោយដោយលំដាប់ គង់លើអបរាជិតបល្ល័ង្ក ទ្រង់កម្ចាត់បង់នូវមារនិងសេនានៃមារ ក្នុងបឋមយាម ទ្រង់សម្រេចនូវបុព្វេនិវាសានុស្សតិញ្ញាណ ក្នុងមជ្ឈិមយាម ទ្រង់សម្រេចនូវទិព្វចក្ខុដ៏បរិសុទ្ធ ញ៉ាំងលោកធាតុមួយម៉ឺនឲ្យកម្រើកញាប់ញ័រ បច្ឆិមយាមចុងក្រោយទ្រង់សម្រេចនូវសព្វញ្ញុតញ្ញាណ ញ៉ាំងពោធិមណ្ឌល ៧ សប្តាហ៍ឲ្យកន្លងទៅ សម្តែងធម្មទេសនា ដែលមហាព្រហ្មអារាធនាហើយ រមិលមើលសត្វលោកដោយពុទ្ធចក្ខុ ហើយនិមន្តទៅកាន់ទីក្រុងពារាណសី ដោយការអនុគ្រោះសត្វលោក ទ្រង់ញ៉ាំងបញ្ច-វគ្គិយឲ្យត្រេកអរហើយ មានព្រះបំណងនឹងប្រកាសធម្មចក្ក ទើបត្រាស់ហៅមកហើយ ។*

**ទ្វេមេ ភិក្ខវេ អន្តា**តិ ទ្វេ ឥមេ ភិក្ខវេ កោដ្ឋាសា ។ ឥមស្ស បន បទស្ស សហ សមុទាហារេន សមុទាហារនិគ្ឃោសោ ហេដ្ឋា អវីចឹ ឧបរិ ភវគ្គំ បត្វា ទសសហស្សិលោកធាតុំ បត្ថរិត្វា អដ្ឋាសិ។ តស្មឹយេវ សមយេ អដ្ឋារសកោដិសង្ខ្យា ព្រហ្មានោ សមាគច្ឆឹសុ, បច្ឆិមទិសាយ សូរិយោ អត្ថមេតិ, ទាចីនទិសាយ អាសាឡ្ហនក្ខត្តេន

យុត្តោ បុណ្ណចន្ទោ ឧគ្គច្ឆតិ ។ តស្មឹ សមយេ ភគវា ឥមំ ធម្មចក្កប្បវត្តនសុត្តំ អារភន្តោ "ទ្វេមេ ភិក្ខវេ អន្តា"តិអាទិមាហ ។

*ពាក្យថា **ម្នាលភិក្ខុទាំងឡាយ ធម៌អមខាង ២ ប្រការនេះ** សេចក្តីថា ម្នាលភិក្ខុទាំងឡាយ ចំណែកធម៌អម ២ ប្រការនេះ ។ ក៏ព្រមជាមួយការត្រាស់ដល់បទនេះ សំឡេងកឹកកង ខាងក្រោមរហូតដល់អវីចីនរក ខាងលើរហូតដល់ភវគ្គព្រហ្ម ផ្សាយទូទៅក្នុងមួយម៉ឺនលោកធាតុ ។ សម័យនោះឯង ព្រហ្មប្រមាណ ១៨ កោដិ មកជុំគ្នាក្នុងទីសម្តែងធម្មចក្ក ។ ដូចព្រះអាទិត្យអស្តង្គតរលត់ទៅ ដូចព្រះចន្ទពេញបូណ៌មី ១៥ កើត ខែអាសាឍ ដែលមានពួកផ្កាយតារាដ៏ព្រោងព្រាតរះឡើងឰដ៏អាកាស ។ សម័យនោះ ព្រះដ៏មានព្រះភាគ កាលទ្រង់ផ្តើមធម្មចក្កប្បវត្តនសូត្រនេះ ទើបត្រាស់ពាក្យជាដើមថា ម្នាលភិក្ខុទាំងឡាយ ធម៌អមខាង ២ ប្រការនេះជាដើម ។*

តត្ថ **បព្ពជិតេនា**តិ គិហិសំយោជនំ ឆិន្ទិត្វា បព្ពជ្ជុបគតេន ។ **ន សេវិតព្វា**តិ ន វឡញ្ជេតព្វា **យោ ចាយំ កាមេសុ កាមសុខល្លិកា-នុយោគោ**តិ យោ ច អយំ វត្ថុកាមេសុ កិលេសកាមសុខស្ស អនុយោគោ ។ **ហីនោ**តិ លាមកោ ។ **គម្មោ**តិ គាមវាសីនំ សន្តកោ ។ **បោថុជ្ជនិកោ**តិ អន្ធពាលជនេន អាចិណ្ណោ ។ **អនរិយោ**តិ ន អរិយោ ន វិសុទ្ធោ ន ឧត្តមោ ន វា អរិយានំ សន្តកោ ។ **អនត្ថសំហិតោ**តិ

ន អត្តសំហិតោ, ហិតសុខាវហាការណំ អនិស្សិតោតិ អត្ថោ។ **អត្តកិលមថានុយោគោ**តិ អត្តនោ កិលមថស្ស អនុយោគោ, អត្តនោ ទុក្ខករណន្តិ អត្ថោ។ **ទុក្ខោ**តិ កណ្ដកាបស្សយសេយ្យាទីហិ អត្តមារណេហិ ទុក្ខាវហោ។

*បណ្ដាបទទាំងឡាយ បទថា **បព្វជិត** សេចក្ដីថា អ្នកកាត់សំយោជនៈនៃគ្រហស្ថ ហើយចូលកាន់ផ្នួស ។ ពាក្យថា **មិនគួរសេពគប់ឡើយ** គឺមិនគប្បីប្រើប្រាស់ ។ ពាក្យថា **ការប្រកបរឿយៗនូវសេចក្ដីជាប់ជំពាក់ដោយកាមសុខ ក្នុងកាមទាំងឡាយ** សេចក្ដីថា ការប្រកបរឿយៗនូវសេចក្ដីជាប់ជំពាក់ដោយកាមសុខក្នុងវត្ថុកាម និងកិលេសកាម ។ ពាក្យថា **ដែលជាធម៌ថោកទាប** គឺធម៌ដ៏លាមក ។ ពាក្យថា **ជារបស់អ្នកស្រុក** គឺជារបស់អ្នកស្រុកទាំងឡាយ ។ ពាក្យថា **ជារបស់បុថុជ្ជន** បានដល់ ជនអន្ធពាលដែលប្រព្រឹត្តរឿយ ៗ ហើយ ។ ពាក្យថា **មិនជារបស់អរិយបុគ្គល** បានដល់ មិនបរិសុទ្ធិ គឺមិនមែនរបស់ខ្ពង់ខ្ពស់ ម្យ៉ាងទៀត មិនមែនរបស់ព្រះអរិយៈទាំងឡាយ ។ ពាក្យថា **មិនប្រកបដោយប្រយោជន៍** គឺមិនមានប្រយោជន៍ អធិប្បាយថា មិនអាស្រ័យហេតុដែលនាំប្រយោជន៍ផ្ទង់ផ្ដើមនិងសេចក្ដីសុខមកឲ្យ ។ ពាក្យថា **ការប្រកបរឿយៗនូវសេចក្ដីព្យាយាមធ្វើខ្លួនឯងឲ្យលំបាក** គឺការប្រកបព្យាយាមធ្វើខ្លួនឲ្យលំបាក អធិប្បាយថា*

*ធ្វើទុក្ខដល់ខ្លួន ។ ពាក្យថា **ដែលនាំមកនូវសេចក្តីទុក្ខ** បានដល់ នាំទុក្ខមកឲ្យដោយការសម្លាប់ខ្លួន មានការដេកលើបន្លាជាដើម ។*

បញ្ញាចក្ខុំ ករោតីតិ **ចក្ខុករណី**។ ទុតិយបទំ តស្សេវ វេវចនំ។ **ឧបសមាយា**តិ កិលេសូបសមត្ថាយ។ **អភិញ្ញាយា**តិ ចតុន្នំ សច្ចានំ អភិជាននត្ថាយ។ **សម្ពោធាយា**តិ តេសំយេវ សម្ពុជ្ឈនត្ថាយ។ **និព្វានាយា**តិ និព្វានសច្ឆិកិរិយាយ។ សេសមេត្ថ យំ វត្តព្វំ សិយា, តំ ហេដ្ឋា តត្ថ តត្ថ វុត្តមេវ។ សច្ចកថាបិ សព្វាការេនេវ វិសុទ្ធិមគ្គេ វិត្ថារិតា។

*ព្រះអង្គទ្រង់ធ្វើបញ្ញាចក្ខុ ព្រោះដូច្នោះ ទើបឈ្មោះថា **ចក្ខុករណី** ។ បទទី ២ ជាវេវចនៈរបស់បទនោះឯង ។ ពាក្យថា ប្រព្រឹត្តទៅដើម្បីសេចក្តីស្ងប់រម្ងាប់ គឺដើម្បីប្រយោជន៍ដល់ការស្ងប់កិលេស ។ ពាក្យថា **ដើម្បីដឹងច្បាស់** គឺដើម្បីប្រយោជន៍ដល់ការដឹងនូវសច្ចៈទាំង៤ ។ ពាក្យថា **ដើម្បីត្រាស់ដឹង** បានដល់ ដើម្បីប្រយោជន៍ដល់ការត្រាស់ដឹងនូវសច្ចៈ ៤ នោះឯង ។ ពាក្យថា **ដើម្បីនិព្វាន** បានដល់ ដើម្បីប្រយោជន៍ដល់ការធ្វើឲ្យជាក់ច្បាស់នូវព្រះនិព្វាន ។ ក្នុងបទនេះពាក្យដ៏សេស ជាពាក្យដែលគប្បី*

ពោលទុក ពាក្យនោះ លោកពោកទុកក្នុងបទនោះជាខាងក្រោយ ។ សូម្បី សច្ចកថាក៏លោកពោលពិស្តារហើយ ក្នុងបករណ៍វិសេស ឈ្មោះវិសុទ្ធិមគ្គ ដោយប្រការទាំងពួងនោះឯង ។

**តិបរិវដ្ដ**ន្តិ សច្ចញាណកិច្ចញាណកតញាណសង្ខាតានំ តិណ្ណំ បរិវដ្ដានំ វសេន តិបរិវដ្ដំ ។ ឯត្ថ ហិ "ឥទំ ទុក្ខំ អរិយសច្ចំ, ឥទំ ទុក្ខសមុទយ"ន្តិ ឯវំ ចតូសុ សច្ចេសុ យថាភូតំ ញាណំ **សច្ចញាណំ** នាម ។ តេសុយេវ "បរិញ្ញេយ្យំ បហាតព្វ"ន្តិ ឯវំ កត្តព្វកិច្ចជានន-ញាណំ **កិច្ចញាណំ** នាម ។ "បរិញ្ញាតំ បហីន"ន្តិ ឯវំ តស្ស តស្ស កិច្ចស្ស កតភាវជាននញាណំ **កតញាណំ** នាម ។ **ទ្វាទសាការ**ន្តិ តេសំយេវ ឯកេកស្មឹ សច្ចេ តិណ្ណំ តិណ្ណំ អាការានំ វសេន ទ្វាទសាការំ ។ **ញាណទស្សន**ន្តិ ឯតេសំ តិបរិវដ្ដានំ ទ្វាទសន្នំ អាការានំ វសេន ឧប្បន្នញាណសង្ខាតំ ទស្សនំ ។ **ធម្មចក្កុ**ន្តិ អញ្ញត្ថ តយោ មគ្គា តីណិ ច ផលានិ ធម្មចក្កុ នាម ហោន្តិ, ឥធ បឋមមគ្គោវ ។

ពាក្យថា **មានបរិវដ្ដ (វិល)** ៣ គឺវិល ៣ ជុំ ដោយអំណាចការវិល ៣ ជុំគឺ សច្ចញាណ កិច្ចញាណ និងកតញ្ញាណ ។ ក៏ក្នុងបរិវដ្ដ ៣ នេះ ញាណប្រព្រឹត្តទៅក្នុងសច្ចៈ ៤ យ៉ាងនេះគឺ នេះទុក្ខអរិយសច្ចៈ នេះទុក្ខសមុទយៈ ឈ្មោះថា **សច្ចញាណ** ។ ញាណដែលជាគ្រឿងដឹងកិច្ចដែលគួរធ្វើយ៉ាងនេះថា គួរកំណត់ដឹង គួរលះក្នុងសច្ចៈនោះឯង ឈ្មោះថា **កិច្ចញាណ** ។ ញាណជាគ្រឿងដឹងការៈនៃកិច្ចនោះ ដែលធ្វើហើយយ៉ាងនេះថា កំណត់ដឹងហើយ លះបានហើយដូច្នេះ ឈ្មោះថា **កតញ្ញាណ** ។ ពាក្យថា មានអាការ ១២ សេចក្ដីថា មានអាការៈ ១២ ដោយអំណាចអាការសច្ចៈនីមួយៗ ៣ នោះឯង ។ ពាក្យថា **ញាណទស្សនៈ** គឺការឃើញ ពោលគឺញាណដែលកើតឡើងហើយ ដោយអំណាចបរិវដ្ដ ៣ យ៉ាង អាការៈ ១២ យ៉ាងនេះឯង ។ ពាក្យថា **ធម្មចក្ក** បានដល់ មគ្គ ៣ និងផល ៣ ក្នុងទីដទៃ ឈ្មោះថា ធម្មចក្ក ។ ក្នុងបទនេះ បានដល់បឋមមគ្គនោះឯង ។

**ធម្មចក្កន្តិ** បដិវេធញាណោ ចេវ ទេសនាញាណោ ច ។ ពោធិបល្លង្កេ និសិន្នស្ស ហិ ចតូសុ សច្ចេសុ ឧប្បន្នំ ទ្វាទសាការំ បដិវេធញាណម្បិ, ឥសិបតនេ និសិន្នស្ស ទ្វាទសាការាយ សច្ចទេសនាយ បវត្តិតំ ទេសនាញាណម្បិ ធម្មចក្កំ នាម ។ ឧភយម្បិ ហេតំ ទសពលស្ស ឧរេ បវត្តញាណមេវ ។ ឥមាយ ទេសនាយ បកាសេន្តេន ភគវតា ធម្មចក្កំ បវត្តិតំ នាម ។ តំ បនេតំ ធម្មចក្កំ

យាវ អញ្ញាសិកោណ្ឌញ្ញត្ថេរោ អដ្ឋារសហិ ព្រហ្មកោដីហិ សទ្ធឹ សោតាបត្តិផលេ បតិដ្ឋាតិ តាវ ឥទំ ភគវា បវត្តេតិ នាម, បតិដ្ឋិតេ ច បវត្តិតំ នាម។ តំ សន្ធាយ **បវត្តិតេ ច បន ភគវតា ធម្មចក្កេ ភុម្មា ទេវា សទ្ទមនុស្សាវេសុន្តិ**អាទិ វុត្តំ។

*ពាក្យថា **ធម្មចក្ក** បានដល់ ញាណជាគ្រឿងចាក់ធ្លុះ និងញាណជាគ្រឿងសម្តែង ។ កាលព្រះមានព្រះភាគទ្រង់គង់លើពោធិបល្ល័ង្ក បដិវេធញាណ មានអាការៈ ១២ កើតឡើងហើយក្នុងសច្ចៈ ៤ ក្តី គង់សូម្បីក្នុងព្រៃឥសិបតនៈ ទេសនាញាណក៏ប្រព្រឹត្តហើយ ដើម្បីសម្តែងសច្ចៈ មានអាការៈ ១២ ក្តី ឈ្មោះថា ធម្មចក្ក ។ ញាណសូម្បីទាំងពីរនោះ ឈ្មោះថាញាណដែលប្រព្រឹត្តទៅក្នុងព្រះហឫទ័យរបស់ព្រះទសពល ។ ធម្មចក្កនោះឯង ព្រះមានព្រះភាគកាលទ្រង់ប្រកាសដោយទេសនានេះ ឈ្មោះថា ទ្រង់ឲ្យប្រព្រឹត្តទៅហើយ ។ ក៏ធម្មចក្កនេះព្រះមានព្រះភាពទ្រង់ឲ្យប្រព្រឹត្ត ដរាបដល់ព្រះអញ្ញាកោណ្ឌញ្ញត្ថេរៈ ជាមួយព្រហ្ម ១៨ កោដិ ទ្រទ្រង់ក្នុងសោតាបត្តិផល ឈ្មោះថា ធម្មចក្កប្រព្រឹត្តទៅហើយ ។ កាលព្រះមានព្រះភាគទ្រង់ឲ្យធម្មចក្កប្រព្រឹត្តិទៅហើយ លោកសំដៅយកពាក្យនោះ ទើបពោលពាក្យជាដើមថា ភុម្មទេវតាទាំងឡាយ ក៏បន្លឺនូវសូរស័ព្ទ ។*

តត្ថ **ភុម្មាតិ** ភូមដ្ឋកទេវតា។ **សទ្ទមនុស្សាវេសុន្តិ** ឯកប្បហារេនេវ សាធុការំ ទត្វា "ឯតំ ភគវតា"តិអាទីនិ វទន្តា

អនុសាវយឹសុ ។ **ឱភាសោ**តិ សព្វញ្ញុតញ្ញាណោភាសោ ។ សោ ហិ តទា ទេវានំ ទេវានុភាវំ អតិក្កមិត្វា វិរោចិត្ថ។ **អញ្ញាសិ វត ភោ កោណ្ឌញ្ញោ**តិ ឥមស្សាបិ ឧទានស្ស ឧទាហារនិគ្ឃោសោ ទស-សហស្សិលោកធាតុំ ផរិត្វា អដ្ឋាសិ។

*បណ្តាបទទាំងនោះ បទថា **ភុម្មា** បានដល់ ទេវតាដែលស្ថិតនៅលើផែនដី ។ ពាក្យថា **បន្ទឺនូវសូរស័ព្ទ** សេចក្តីថា ទេវតាទាំងឡាយ ឲ្យសាធុការព្រមគ្នាតែម្តង ពោលពាក្យជាដើមថា **ធម្មចក្កនេះ មិនមានចក្កដទៃក្រៃលែងជាង...** ដូច្នេះប្រកាសឲ្យបានឮហើយ ។ ពាក្យថា **ពន្លឺ** បានដល់ ពន្លឺ គឺសព្វញ្ញុតញ្ញាណ ។ ពិតយ៉ាងនោះ ពន្លឺគឺសព្វញ្ញុតញ្ញាណនោះ ក្លឺកន្លងលើសអានុភាពរបស់ទេវតាទាំងឡាយ ។ ពាក្យថា **អើហ្ន៎ កោណ្ឌញ្ញៈ បានត្រាស់ដឹងពិតហើយ** សេចក្តីថា សំឡេងកងរំពងនៃព្រះឧទាននេះ ក៏លាន់ឮឡើង ដរាបដល់មួយម៉ឺនលោកធាតុ ។*

ឥតិ សាធុជនចាមុជ្ជត្ថាយ សារត្ថប្បសានិយំ

ធម្មចក្កប្បវត្តនសុត្តវណ្ណនា និដ្ឋិតា ។

*អដ្ឋកថាពណ៌នាធម្មចក្កប្បវត្តនសូត្រ ក្នុងគម្ពីរសារត្ថប្បកាសិនី*
*ដើម្បីកើតបាមោជ្ជៈដល់សាធុជន ចប់ដោយប្រការយ៉ាងនេះ ។*

ឯវំ ធម្មំ ទេសេន្តោ បឋមវស្សំ ពារាណសឹ ឧបនិស្សាយ ឥសិបតនេ មិគទាយេ វសិ ។ ទុតិយវស្សំ រាជគហំ ឧបនិស្សាយ វេឡុវនមហាវិហារេ វសិ ។ តតិយចតុត្ថានិបិ តត្ថេវ ។ បញ្ចមំ វេសាលឹ ឧបនិស្សាយ មហាវនេ កូដាគារសាលាយំ ។ ឆដ្ឋំ មកុឡបព្វតេ ។ សត្តមំ តាវត្តឹសភវនេ ។ អដ្ឋមំ ភគ្គេ សុំសុមារគិរឹ និស្សាយ ភេសកឡាវនេ ។ នវមំ កោសម្ពិយំ ។ ទសមំ ចាលិលេយ្យកវនសណ្ឌេ ។ ឯកាទសមំ នាឡាយំ ព្រាហ្មណគាមេ ។ ទ្វាទសមំ វេរញ្ជាយំ ។ តេរសមំ ចាលិយបព្វតេ ។ ចុទ្ទសមំ ជេតវនមហាវិហារេ ។ បញ្ចទសមំ កបិលវត្ថុមហាវិហារេ ។ សោឡសមំ អាឡវកំ ទមេត្វា ចតុរាសីតិបាណសហស្សានិ អមតបានំ បាយេត្វា អាឡវិយំ ។ សត្តរសមំ រាជគហេយេវ ។ អដ្ឋារសមំ ចាលិយបព្វតេយេវ ។ តថា ឯកូនវីសតិមំ ។ វីសតិមំ បន វស្សំ រាជគហេយេវ វសីតិ ឯវំ ភគវា បឋមពោធិយំ វីសតិវស្សានិ អនិពទ្ធវាសោ ហុត្វា យត្ថ យត្ថ ផាសុកំ ហោតិ, តត្ថ តត្ថេវ ចរន្តោ វសិ ។ តតោ បដ្ឋាយ បន បញ្ចវីសតិវស្សានិ សាវត្ថឹ ឧបនិស្សាយ ជេតវនមហាវិហារេ បុព្វារាមេ ច ធុវបរិភោគេន វសិ ។

កាលព្រះដ៏មានព្រះភាគទ្រង់សម្តែងធម៌យ៉ាងនេះ ទ្រង់គង់ចាំវស្សាទី ១ ក្នុងព្រៃឥសិបតនមិគទាយវ័ន ជិតក្រុងពារាណសី ។ វស្សាទី ២-៣-៤ គង់ចាំវស្សាក្នុងវេឡុវ័នមហាវិហារ ជិតក្រុងរាជគ្រឹះ ។ វស្សាទី ៥ ទ្រង់គង់ចាំវស្សាក្នុងកូដាគារសាលានាព្រៃមហាវ័ន ជិតក្រុងវេសាលី ។ វស្សាទី ៦ គង់ចាំវស្សាលើភ្នំមកុឡបព៌ត ។ វស្សាទី ៧ គង់ចាំវស្សាក្នុងស្ថានតាវត្តិង្ស ។ វស្សាទី ៨ ទ្រង់ចាំវស្សាក្នុងភេសកឡាវ័ន ជិតភ្នំសុំសុមារគិរីក្នុងដែនភគ្គៈ ។ វស្សាទី ៩ គង់ចាំវស្សាក្នុងក្រុងកោសម្ពី ។ វស្សាទី ១០ គង់ចាំវស្សាក្នុងព្រៃបាលិលេយ្យក៍ ។ វស្សាទី ១១ គង់ចាំវស្សាក្នុងស្រុកព្រាហ្មណ៍ ឈ្មោះនាឡា ។ វស្សាទី ១២ គង់ចាំវស្សាក្នុងក្រុងវេរញ្ជា ។ វស្សាទី ១៣ គង់ចាំវស្សាលើចាលិយបព៌ត ។ វស្សាទី ១៤ គង់ចាំវស្សាក្នុងវត្តជេតពនមហាវិហារ ។ វស្សាទី ១៥ គង់ចាំវស្សាក្នុងមហាវិហារក្រុងកបិលពស្តុ ។ វស្សាទី ១៦ ទ្រង់គង់ចាំវស្សាក្នុងក្រុងអាឡវី បន្ទាប់ពីបានទូន្មានអាឡវកយក្ខ ញុំាងសត្វ ៨៤,០០០ នាក់ ឲ្យផឹកទឹកអម្រឹត។ វស្សាទី ១៧ គង់ចាំវស្សាក្នុងក្រុងរាជគ្រឹះ ។ វស្សាទី ១៨-១៩ គង់ចាំវស្សាលើភ្នំចាលិយបព៌ត ។ វស្សាទី ២០ គង់ចាំវស្សាក្នុងក្រុងរាជគ្រឹះ ។ រួមសេចក្តីតាមពោលមកនេះ មានប្រមាណ ២០ វស្សា ហៅថា បឋមពោធិកាល គឺគ្រាដំបូងនៃការត្រាស់ដឹង ព្រះដ៏មានព្រះភាគពុំបានគង់ចាំវស្សាជាប្រចាំមួយកន្លែង ព្រះអង្គនិមន្តចារិកទៅគង់វស្សាក្នុងស្ថានទីដែលមានសេចក្តីសប្បាយ ។ ក្រោយពី ២០ វស្សានោះ ព្រះដ៏មានព្រះភាគ

ទ្រង់គង់នៅជាប្រចាំ ក្នុងវត្តជេតពនមហាវិហារនិងវត្តបុព្វារាម ទៀបក្រុងសាវត្ថី ចំនួន ២៥ វស្សា ។

ឯវំ សត្ថា សម្ពោធឹ បត្វា បញ្ចត្តាឡីសវស្សានិ ជីវមានោ ធម្មចក្កប្បវត្តនសុត្តន្តទេសនតោ បដ្ឋាយ យាវ បរិនិព្វានមញ្ចេ និបជ្ជិត្វា សុភទ្ទបរិព្វាជកវិនយនា តយោ បិដកេ ទេសេន្តោ ចតុវីសតិ អសង្ខ្យេយ្យប្បមាណេ សត្តេ អមតមហានិព្វានរសំ ទាយន្តោ អជរាមរេ អកាសីតិ ។

ក្រោយពេលដែលទ្រង់សម្រេចនូវសម្មាសម្ពោធិញ្ញាណ យ៉ាងនេះហើយ ព្រះសាស្តាគង់ព្រះជន្មនៅបាន ៤៥ វស្សា ទ្រង់សម្តែងព្រះត្រៃបិដក ចាប់តាំងពីធម្មចក្កប្បវត្តនសូត្រ រហូតដល់ទៅផ្ទុំលើគ្រែបរិនិព្វាន ហើយទ្រង់ណែនាំបង្រៀនសុភទ្ទបរិព្វាជក ទ្រង់ញ៉ាំងសត្វប្រមាណ ២៤ អសង្ខេយ្យ ឲ្យក្រេបផឹកនូវរសនៃអមតមហានិព្វាន ដែលមិនចាស់ មិនស្លាប់ ។

ឥតិ សាធុជនានន្ទនាននិទានេ ធម្មចក្កប្បវត្តនេ

ទេសនាញាណវណ្ណនា និដ្ឋិតា ។

ទេសនាញាណវណ្ណនា ក្នុងធម្មចក្កប្បវត្តនៈ

សម្រាប់ឲ្យកើតសេចក្តីរីករាយដល់សាធុជន ចប់តែប៉ុណ្ណោះ ។

ការទទួលយកទៅបោះពុម្ពផ្សាយជាធម្មទាន

ក្រោមការឧបត្ថម្ភបោះពុម្ពរបស់មូលនិធិពុទ្ធិកសិក្សានៅតៃវ៉ាន់

(The Corporate Body of the Buddha Educational Foundation) ។

ដោយអាស្រ័យលើការមើលឃើញនូវកត្តាចាំបាច់មួយចំនួនដូចខាងក្រោម៖

- រក្សាស្នាដៃវប្បធម៌ព្រះពុទ្ធសាសនាឲ្យគង់វង្សស្ថិតស្ថេរ
- តម្រូវការរបស់សិក្ខាកាមអ្នកប្រាថ្នាចង់យល់ដឹងនូវខ្លឹមសារពុទ្ធសាសនា
- ផ្សាយនូវធម្មទាន ធ្វើឲ្យព្រះពុទ្ធសាសនាកាន់តែមានភាពរីកចម្រើនរុង-រឿងក្នុងលោក

ក្នុងករណីដែលលោកអ្នកអានបានប្រទះឃើញនូវសៀវភៅនេះមានដាក់លក់

នៅកន្លែងណា ឬចង់បានសៀវភៅធម៌យកទៅអាន

សូមទាក់ទងមកយើងខ្ញុំតាមអាសយដ្ឋានដូចខាងក្រោមៈ

វត្តបញ្ញា សង្កាត់ក្រាំងធ្នង់ ខណ្ឌសែនសុខ រាជធានីភ្នំពេញ

លេខទូរស័ព្ទៈ (៨៥៥) ១២ ៩៦១ ៤២៩, (៨៥៥) ៨៨៧ ៩៦១ ៤២៩

អ៊ីមែលៈ maha.panna@gmail.com

គេហទំព័រៈ http://www.mahapanna.org

*"Wherever the Buddha's teachings have flourished,*

*either in cities or countrysides,*
*people would gain inconceivable benefits.*
*The land and people would be enveloped in peace.*
*The sun and moon will shine clear and bright.*
*Wind and rain would appear accordingly,*
*and there will be no disasters.*
*Nations would be prosperous*
*and there would be no use for soldiers or weapons.*
*People would abide by morality and accord with laws.*
*They would be courteous and humble,*
*and everyone would be content without injustices.*
*There would be no thefts or violence.*
*The strong would not dominate the weak*
*and everyone would get their fair share."*

~THE BUDDHA SPEAKS OF
THE INFINITE LIFE SUTRA OF
ADORNMENT, PURITY, EQUALITY
AND ENLIGHTENMENT OF
THE MAHAYANA SCHOOL~

# DEDICATION OF MERIT

May the merit and virtue
accrued from this work
adorn Amitabha Buddha's Pure Land,
repay the four great kindnesses above,
and relieve the suffering of
those on the three paths below.

May those who see or hear of these efforts
generate Bodhi-mind,
spend their lives devoted to the Buddha Dharma,
and finally be reborn together in
the Land of Ultimate Bliss.
Homage to Amita Buddha!

**NAMO AMITABHA**

**南無阿彌陀佛**

《柬埔寨文：The Journey of The Buddha Enlightenment and Wheel Turning Sutra, 佛陀證悟的旅程及轉法輪經》

財團法人佛陀教育基金會 印贈

台北市杭州南路一段五十五號十一樓

Printed and donated for free distribution by

**The Corporate Body of the Buddha Educational Foundation**

11F., 55 Hang Chow South Road Sec 1, Taipei, Taiwan, R.O.C.
Tel: 886-2-23951198 , Fax: 886-2-23913415
Email: overseas@budaedu.org
Website:http://www.budaedu.org
Mobile Web: m.budaedu.org

**This book is strictly for free distribution, it is not to be sold.**

សម្រាប់ចែកជាធម្មទាន

Printed in Taiwan
3,000 copies; September 2015
CA063 - 13505